# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនាៈ ព្រះគ្រូបញ្ញាលិក្ខិត កៅ-ស៊ុម អ្នកគ្រូគ្រាសិស្ស នៅសាលាបាលីជាន់ខ្ពស់

---

## បញ្ជីរឿង

*ផ្នែកអក្សរសាស្ត្រ* — *ទំព័រ*

ឃុនបណ្ណានុរក្ស ប៊ូ-ប៊ូ . . . . តំលៃសិល្បសាស្ត្រ . . . . . . . . . . ៥៦១

លោក ហាន់-យេង . . . . . . រឿងកំពូលកំសត់ (តមក) . . . . . . . . ៥៧១

ឃុនឧត្តមប្រីជា ឆាប-ពិន . . បណ្ដាំ (តមកនិងចប់) . . . . . . . . ៥៨២

*ផ្នែកសាសនា*

លោកគ្រូចៅអធិការ ឯក-ញឹម . ធម្មបទភាសិត . . . . . . . . . . . . ៥៩៤

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម . . . ឯកភាពនៃមិលិន្ទប្បញ្ហា (តមក) . . . . . - ៦០៦

ពុទ្ធសាសនបណ្ឌិត្យ . . . . អំពីព្រះរាជទានតាំងសមណស័ក្តិ នៅវត្តបទុមវតី . . . . . . . . . . . ៦១៣

---

ឆ្នាំទី ១៦ – លេខ ១១ ខែណូវែមប្រ៏ ឆ្នាំ ១៩៤៤ – តំលៃជាវៈ ១ ឆ្នាំ ១៥ រៀល ។

# KĂMPŬCHĔASŎRĬYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire: Luong Nibandhamantri Nhok-Thêm, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse: Preah kru Paññalikhito Kao-Sim, Surveillant général de l'École Supérieure de Pāli.

## TABLE DES MATIÈRES

**Partie littéraire:**


| | | Pages |
|---|---|---|
| K'ŭn Pannanurak Bou-Po | Dămlĕi sĕlpăsas . . . . . . . . | 561 |
| Monsieur Han-Yéng. . . . | Kămpul kămsăt, roman (suite). . | 570 |
| K'ŭn Ŏtdăm Preichea Chap-Pinn . . . . . . | Băndau (devinettes cambodgiennes) (suite et fin) . . . . . . . . . | 582 |


**Partie religieuse:**


| | | |
|---|---|---|
| Vénérable Chau At'ĭkar Ek-Nhim . . . . . | T'ĕammăbăt p'easĕt . . . . . . . | 594 |
| Luong Nĭponmontrei Nhok-Thêm . . . . . . . | Ekabhāga-Milindapañhā (suite). . | 606 |
| Institut Bouddhique . . . | Compte-rendu de la remise solennelle des titres aux nouvaux Reacheakĕană, à Vĕat Bĭtŭmăvĕadei . . . . . . . . | 613 |

# ដំនៀសិល្បសាស្ត្រ

យុទបណ្ណា ទុរក្ស ប៊ូ-ប៊ូ រៀបរៀង

## “ប្រាជ្ញាបុណ្យផង កើតដោយប្រតិបត្តិ[១]”

សេចក្តីចេះដឹងសិល្បសាស្ត្រមន្តវិជ្ជាការគ្រប់យ៉ាង មានចេះអក្សរ នឹងលេខជាដើម ហៅថាប្រាជ្ញា ។ នេះកើតមានឡើងដោយសារតែបាន រៀនសូត្រអំពីសំណាក់គ្រូអាចារ្យ ។

សេចក្តីសុខ, សេចក្តីចំរើន, យសស័ក្តិ, សម្បត្តិទ្រព្យនឹងផល ប្រយោជន៍ទាំងអស់ក្នុងលោកនេះ ហៅថាបុណ្យ ។ នេះកើតឡើងដោយ សារតែមានសេចក្តីព្យាយាមខំរៀនសូត្រ ឬខំធ្វើការរកស៊ីនឹងបានកាន់ ច្បាប់ទម្លាប់ស្តាប់ដម្បូន្មានមាតាបិតាគ្រូអាចារ្យ មិនហ៊ានប្រព្រឹត្តកន្លង ។

ការប្រព្រឹត្ត, កាន់, ធ្វើតាម ហៅថាប្រតិបត្តិ ។ មនុស្សដែល បានសម្រេចផលប្រយោជន៍ គឺមានប្រាជ្ញាឬមានបុណ្យស័ក្តិកើតដោយ ប្រតិបត្តិនោះ ដូចជាមាន :

## រឿងគ្រូពេទ្យជីវកកោមារភត្យ[២]

ក្រុងវេសាលីជាក្រុងស្តុកស្តម្ភធំទូលាយ មានមនុស្សកុះករច្រើនម៉ឺន ដេរដាស មានអាហារចំណីសម្បូណ៌ មានប្រាសាទ ៧.៧០៧ មាន ផ្ទះកំពូល ៧.៧០៧, មានសួនច្បារ ៧. ៧០៧, មានស្រះបោក្ខរណី ៧.៧០៧, មានស្រីផ្កាមាសម្នាក់ឈ្មោះនាងអម្ពបាលី មានរូបល្អគួរ

---

១ ច្បាប់ក្រម ។ ២ វិនយបិដក មហាវគ្គ ចីវរក្ខន្ធក ។

ពិតពិលរមិលមើល គួរឲ្យស្រឡាញ់ ត្រូវចិត្តមនុស្សពន់ពេក ជាស្រីប្រសប់លេងល្បែងរាំច្រៀងដេញដំប្រគំ ពួកមនុស្សជាច្រើននាក់តែងនាំគ្នាចូលទៅរកនាងនោះៗ ក្នុង១ យប់យកថ្លៃ ៥០ រៀល ក្រុងវេសាលីសឹងបានចំរើនរុងរឿងដោយសារតែនាងអម្ពបាលីនេះឯង ។

គ្រានោះ មានពួកកុដុម្ពីនៅក្រុងរាជគ្រឹះបានទៅឯក្រុងវេសាលីដោយមានកិច្ចណាមួយ បានសង្កេតមើលការរចនាបែបភាពលំអរបស់ក្រុងវេសាលីសព្វគ្រប់ហើយបានតាំងឃើញនាងអម្ពបាលីនោះផង លុះមើលឃើញសព្វគ្រប់ស្រេចហើយក៏ត្រឡប់មកក្រុងរាជគ្រឹះវិញ បានចូលទៅគាល់ព្រះបាទពិម្ពិសារក្រាបបង្គំទូលអំពីការរចនាបែបភាពលំអរបស់ក្រុងវេសាលីទាំងអស់តាមដែលខ្លួនបានឃើញ ហើយក្រាបបង្គំទូលសូមអនុញ្ញាតតាំងស្រីផ្កាមាសម្នាក់ក្នុងក្រុងរាជគ្រឹះផង លុះស្ដេចទ្រង់ត្រាស់អនុញ្ញាតហើយ ពួកកុដុម្ពីក៏បានតាំងនាងកុមារីម្នាក់ឈ្មោះសាលវតី មានរូបល្អគួរឲ្យចង់មើល គួរឲ្យស្រឡាញ់ មានសម្បុរល្អ ត្រូវចិត្តមហាជនពន់ពេកឲ្យធ្វើជាស្រីផ្កាមាស នាងនេះប្រសប់លេងល្បែងរាំច្រៀងដេញដំប្រគំ មានប្រុសៗស្រឡាញ់ចូលចិត្តទៅរកនាងជាច្រើន នាងនេះក្នុង១ យប់យកថ្លៃ ១០០ រៀល ។

នាងសាលវតីធ្វើជាស្រីផ្កាមាសមិនយូរប៉ុន្មានក៏មានគភ៌ ទើបនាងរិះគិតថា ធម្មតាស្រីតែមានគភ៌ហើយ ប្រុសៗមិនសូវពេញចិត្តឡើយ

ប្រសិនបើគេដឹងថាអញមានគភ៌ មុខជាអញលែងបានប្រាក់មាសហើយ បើដូច្នោះមានតែអញប្រាប់គេថា ខ្លួនអញឈឺ គិតហើយក៏ផ្តាំនាយទ្វារថា នែនាយទ្វារ អ្នកឯងហាមកុំឲ្យប្រុសណាមួយចូលមករកខ្ញុំឡើយ បើមាននរណាមកសួររកខ្ញុំ ត្រូវអ្នកឯងប្រាប់ថា នាងសាលវតីឈឺទៅហើយ ៗ លុះដល់នាងសាលវតីមានគភ៌គ្រប់ខែហើយក៏សម្រាលកូនប្រុស ១ មក នាងបង្គាប់ឲ្យខ្ញុំស្រីដាក់ទារកក្នុងចង្អេរចាស់ហើយឲ្យយកទៅដាក់ចោលលើគំនរសម្រាម ជួនជាពេលនោះ ព្រះអភយរាជកុមារចេញទៅគាល់ស្តេចពីព្រលឹម បានក្រឡេកមើលទៅឃើញទារកនៅលើគំនរសម្រាមមានសត្វក្អែកចោមរោមជុំវិញ ក៏ប្រើមនុស្សឲ្យរើសយកទារកនោះទៅក្នុងវាំងប្រគល់ឲ្យមេដោះចិញ្ចឹមហើយសន្មតឲ្យឈ្មោះថាជីវក ដោយហេតុទារកនោះនៅរស់ ក្រោយមកទៀតឲ្យឈ្មោះថាកោមារភច្ច ដោយហេតុទារកនោះអភយរាជកុមារបានរើសយកមកចិញ្ចឹមរក្សា រួមឈ្មោះទាំងមុខទាំងក្រោយហៅភ្ជាប់គ្នាថាជីវកកោមារភច្ចៗកាលចំរើនធំឡើងបានដឹងក្តីហើយ ក៏ចូលទៅគាល់អភយរាជកុមារក្រាបទូលសួរថា បពិត្រព្រះសម្មតិទេព ស្រីណាជាមាតារបស់ខ្ញុំប្រុសណាជាបិតារបស់ខ្ញុំ អភយរាជកុមារត្រាស់ប្រាប់ថា ហៃបាជីវកអើយទុកជាខ្លួនអញក៏មិនបានស្គាល់ម្តាយឪពុកបាឯងដែរ ប៉ុន្តែខ្លួនអញទុកដូចជាឪពុកបាឯងចុះ ព្រោះអញរើសយកឯងពីគំនរសម្រាមមកចិញ្ចឹមរក្សា

ជីវកកោមារភច្ចឮដូច្នោះគិតថា ពួករាជត្រកូលនេះតែគ្មានសិល្បសាស្ត្រហើយ មិនអាចនឹងចិញ្ចឹមជីវិតបានស្រួលទេ បើដូច្នោះមានតែអញរករៀនសិល្បសាស្ត្រ លុះគិតហើយក៏លបចេញពីសំណាក់អភយរាជកុមារដើរសំដៅទៅឯក្រុងតក្កសិលាបានចូលទៅសុំរៀនក្នុងសំណាក់អាចារ្យទិសាបាមោក្ខ(១) ដែលមានវិជ្ជាពេទ្យ រៀនសិល្បសាស្ត្រនេះបានច្រើនឆាប់រហ័សណាស់ឥតភ្លេចភ្លាំងទៅវិញឡើយ ។

ជីវកកោមារភច្ចនៅរៀនវិជ្ជាពេទ្យបានចំនួន ៧ ឆ្នាំ ក៏នឹកឆ្ងល់ថា អញរៀនក្បួនពេទ្យនេះចំនួន ៧ ឆ្នាំមកហើយ មិនដឹងជាកាលណានឹងរៀនចប់ឡើយ ទើបចូលទៅជំរាបសួរគ្រូថា បពិត្រលោកអាចារ្យ កាលណាខ្ញុំនឹងរៀនវិជ្ជាពេទ្យនេះចប់ អាចារ្យទិសាបាមោក្ខប្រាប់ថា នែជីវក បើអ្នកឯងសង្ស័យដូច្នោះ ចូរអ្នកកាន់ចបជីកដើរចេញទៅចម្ងាយ ១ យោជន៍ ជុំវិញក្រុងតក្កសិលា ហើយរកមើលស្មៅឬឈើណាដែលធ្វើជាថ្នាំមិនកើត ចូរអ្នកយកស្មៅឬឈើនោះមកបង្ហាញខ្ញុំ ជីវកកោមារភច្ចកាន់ចបជីកដើរទៅតាមបង្គាប់អាចារ្យ ឥតឃើញមានស្មៅឬឈើណាដែលធ្វើជាថ្នាំមិនកើតឡើយ ឃើញសុទ្ធតែធ្វើថ្នាំបានទាំងអស់ឥតសល់ ទើបវិលចូលមកជំរាបអាចារ្យវិញ អាចារ្យប្រាប់ថា នែជីវក វិជ្ជាពេទ្យយើងបានបង្រៀនអ្នកចប់សព្វគ្រប់អស់ហើយ បំណោះ

---

១ ជាប្រធានក្នុងទិស គឺអាចារ្យដែលចេះដឹងនានាវិជ្ជាពូកែល្បីឈ្មោះទៅគ្រប់ទិស ។

របស់អ្នកឯងប៉ុណ្ណោះព្រមទឹងចិញ្ចឹមជីវិតបានហើយ ចូរអ្នកវិលទៅនៅស្រុកវិញចុះ ថាហើយក៏ឲ្យស្បៀងបន្តិចបន្តួចគ្រាន់ទឹងអាស្រ័យតាមផ្លូវ ជីវកកោមារភត្យទទួលយកស្បៀងហើយ សំពះលាអាចារ្យចេញពីនគរតក្កសិលាដើរសំដៅទៅក្រុងរាជគ្រឹះ លុះដើរទៅដល់ពាក់កណ្ដាលផ្លូវជិតនឹងដល់ក្រុងសាកេតក៏អស់ស្បៀងរលីង ទើបជីវកកោមារភត្យគិតថា ផ្លូវអស់ទាំងនេះជាផ្លូវដាច់ស្រយាល ក្របាយទឹកចំណីអាហារណាស់ នរណាឥតស្បៀងអាហារដើរទៅផ្លូវនេះមិនរួចទេ បើដូច្នោះមានតែអញស្វែងរកស្បៀងឲ្យបានសិនរួចសឹមទៅ ។

គ្រានោះ ក្នុងក្រុងសាកេត មានភរិយាសេដ្ឋីម្នាក់កើតរោគឈឺក្បាល ៧ ឆ្នាំមកហើយ ពួកគ្រូពេទ្យយ៉ាងធំៗ ច្រើននាក់ នាំគ្នាមកព្យាបាលរោគនោះមិនជា យកតែរង្វាន់អស់ជាច្រើន ជីវកកោមារ-ភត្យបានដឹងដំណឹងនោះហើយក៏ចូលទៅឯលំនៅសេដ្ឋី ប្រើនាយទ្វារឲ្យចូលទៅជំរាបភរិយាសេដ្ឋីៗ សួរថាគ្រូពេទ្យនោះតើក្មេងឬចាស់ នាយទ្វារជំរាបថា បពិត្រអ្នកម្ចាស់ គ្រូពេទ្យនោះនៅក្មេងទេ ភរិយាសេដ្ឋីឆ្លើយថា ណ្ហើយកុំ នាយទ្វារ បើគ្រូពេទ្យនៅក្មេងម៉្លេះធ្វើម្ដេចនឹងមើលរោគអញជា ដ្បិតមានគ្រូពេទ្យយ៉ាងធំៗ ច្រើននាក់មកមើលមិនជាទៅហើយ យកតែរង្វាន់អស់ជាច្រើន នាយទ្វារចេញទៅប្រាប់ជីវក-កោមារភត្យវិញតាមពាក្យភរិយាសេដ្ឋីគ្រប់ប្រការ ជីវកកោមារភត្យ

ប្រើនាយទ្វារឲ្យទៅជំរាបម្ដងទៀតថា អ្នកម្ចាស់កុំអាលឲ្យវត្ថុអ្វីមុនឡើយ ចាំអ្នកម្ចាស់ជារោគពេលណា បើចង់ឲ្យរបស់អ្វី ក៏ឲ្យពេលនោះចុះ នាយទ្វារចូលទៅជំរាបភរិយាសេដ្ឋី ៗ ក៏ព្រមបើកឲ្យចូលទៅ លុះជីវកកោមារភច្ច ចូលទៅដល់ហើយក៏សង្កេតមើលអាការរោគបានស្គាល់ច្បាស់ ទើបសុំទឹកដោះគោអំពីភរិយាសេដ្ឋី ១ ទូកដៃយកមកស្លលាយនឹងថ្នាំច្រើនមុខទៀត ឲ្យភរិយាសេដ្ឋីដេកផ្ងារលើគ្រែហើយបញ្ចុកថ្នាំនោះ ៗ ក៏ខ្ទរចេញពីមាត់មកវិញ ភរិយាសេដ្ឋីខ្ជាក់ថ្នាំនោះទៅក្នុងកន្ថោរ ហើយប្រើខ្ញុំស្រីឲ្យយកសំឡីមកផ្ដិតយកទឹកដោះគោទុក ជីវកកោមារភច្ចបានឃើញដូច្នោះគិតថា យីអើ អស្ចារ្យអ្វីម្ល៉េះ ស្រីមេផ្ទះនេះកម្រណាស់តើ មិនសមបើហ៊ាននៅប្រើខ្ញុំស្រីឲ្យយកសំឡីមកផ្ដិតទឹកដោះគោនេះទុកសោះ ឯទឹកដោះនេះសមតែចាក់ចោលទៅវិញទេ ១ ទៀតអញប្រើថ្នាំថ្លៃ ៗ អស់ជាច្រើនទៅហើយ ស្រីនេះនឹងឲ្យរង្វាន់តែបន្តិចបន្តួចដល់អញម្ដេចបាន ឯភរិយាសេដ្ឋីស្គាល់អាការទឹកមុខជីវកកោមារភច្ច ប្រែប្លែកដូច្នោះក៏ប្រាប់ថា នែលោកគ្រូពេទ្យ យើងជាស្រីគ្រប់គ្រងផ្ទះ ត្រូវតែចេះសំចៃទឹកដោះគោនេះទុក ដ្បិតទឹកដោះគោនេះនឹងធ្វើជាថ្នាំលាបជើងពួកទាសកម្មករក៏បាននឹងចាក់ចង្កៀងអុជក៏បាន លោកកុំតូចចិត្តឡើយ រង្វាន់របស់លោកមុខជាមិនខូចខាតទេ ជីវកកោមារភច្ចបញ្ចុកថ្នាំភរិយាសេដ្ឋីតែម្ដងប៉ុណ្ណោះ ក៏សះជារោគឈឺក្បាលស្រឡះភ្លាម ទើបភរិយាសេដ្ឋីឲ្យរង្វាន់

៤ ពាន់រៀល កូនប្រុសនិងកូនប្រសាស្រីបានដឹងថាម្តាយខ្លួនជាជម្ងឺហើយ ក៏ឲ្យរង្វាន់ ៤ ពាន់រៀលម្នាក់ៗទៀត ឯសេដ្ឋីជាស្វាមីក៏បានឲ្យប្រាក់រង្វាន់ ៤ ពាន់រៀលផងឲ្យខ្ញុំប្រុសខ្ញុំស្រីនិងរថទឹមសេះថែមទៀតផង រួមទាំងប្រាក់ទាំងអស់បាន ១៦ ពាន់រៀល ជីវកកោមារភច្ចទទួលយករង្វាន់ទាំងអស់នោះចេញទៅឯក្រុងរាជគ្រឹះ លុះទៅដល់ក្រុងរាជគ្រឹះហើយបានចូលទៅគាល់អភយរាជកុមារក្រាបទូលថា សូមទ្រង់មេត្តាប្រោស រង្វាន់ទាំងអស់នេះហើយដែលជាស្នាដៃដំបូងរបស់ទូលបង្គំជាខ្ញុំ សូមព្រះសម្មតិទេពទ្រង់ទទួលយកថ្លៃស្រោមចិញ្ចឹមទូលបង្គំជាខ្ញុំចុះ អភយរាជ-កុមារឆ្លើយថា នែនាយជីវក ណ្ហើយកុំ របស់ទាំងនេះស្រេចនឹងអ្នកឯងចុះ ប៉ុន្តែត្រូវអ្នកឯងសង់ផ្ទះនៅក្នុងវាំងយើង ជីវកកោមារភច្ចក៏ព្រមធ្វើតាមព្រះបន្ទូល ។

កាលជាបំណោរមក ព្រះបាទពិម្ពិសារទ្រង់កើតព្រះរោគឫសដូងបាតបានត្រាស់ហៅជីវកកោមារភច្ចឲ្យមកព្យាបាលព្រះរោគនោះ ជីវក-កោមារភច្ចបានយកថ្នាំចំនួនមួយក្រចកដាក់លាបផ្សះព្រះរោគឫសដូងបាតនោះតែម្តងប៉ុណ្ណោះ ព្រះរោគក៏សះជាដាច់ស្រឡះ ទើបព្រះបាទពិម្ពិសារទ្រង់ត្រាស់បង្គាប់ឲ្យស្រីៗប្រាំរយនាក់ស្អិតស្អាងគ្រឿងអលង្ការគ្រប់ប្រដាប់ហើយឲ្យដោះចេញគរជាគំនររួចទ្រង់ព្រះរាជទានគ្រឿងអលង្ការ ១ គំនរព្រមទាំងស្រីប្រាំរយនាក់នោះផងឲ្យជីវកកោមារភច្ច ។

ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស កុំព្រួយព្រះរាជហឫទ័យឡើយ សូមព្រះសម្មតិទេពគ្រាន់តែទ្រង់រឭកឧបការរបស់ខ្ញុំព្រះអង្គចុះ ព្រះបាទពិម្ពិសារទ្រង់ត្រាស់ថា បើដូច្នោះ ចូរអ្នកឯងបម្រើយើងផង បម្រើស្រីស្នំផង បម្រើភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានផង ជីវកកោមារភច្ចក៏ទទួលបម្រើតាមព្រះរាជឱង្ការ ។

ក្រោយពីនោះមកទៀត មានសេដ្ឋីម្នាក់នៅក្រុងរាជគ្រឹះកើតរោគឈឺក្បាល ៧ ឆ្នាំមកហើយ ពួកគ្រូពេទ្យធំៗមើលពុំជា យកតែរង្វាន់អស់ជាច្រើនហើយរត់ចោលលែងមើលទៅ មានពួកគ្រូពេទ្យខ្លះទាយថា នៅតែ ៥ ថ្ងៃទៀតសេដ្ឋីមុខជានឹងស្លាប់ មានពួកគ្រូពេទ្យខ្លះទាយថា នៅតែ ៧ ថ្ងៃទៀតសេដ្ឋីមុខជានឹងស្លាប់ វេលានោះមានពួកកុដុម្ពីបានចូលទៅគាល់ព្រះបាទពិម្ពិសារសូមព្រះរាជានុញ្ញាតឲ្យជីវកកោមារភច្ចទៅព្យាបាលរោគសេដ្ឋីនោះ ឯជីវកកោមារភច្ចកាលបានទទួលព្រះរាជានុញ្ញាតហើយក៏ចូលទៅឯលំនៅសេដ្ឋី លុះទៅដល់ហើយបានពិនិត្យមើលអាការរោគក្នុងខ្លួនសេដ្ឋីក៏ដឹងជាក់ច្បាស់ ទើបសួរសេដ្ឋីថា នែគហបតី ប្រសិនបើខ្ញុំមើលជម្ងឺលោកជា តើលោកនឹងឲ្យអ្វីខ្ញុំ សេដ្ឋីឆ្លើយថា លោកគ្រូពេទ្យ ខ្ញុំជូនសម្បត្តិទ្រព្យរបស់ខ្ញុំទៅលោកទាំងអស់ ទាំងខ្លួនខ្ញុំសោតក៏ទៅនៅបម្រើធ្វើជាខ្ញុំលោកទៀត ជីវកកោមារភច្ចសួរថា បើដូច្នោះលោកសម្រាន្តផ្អៀងតែម្ខាងចំនួន ៧ ខែបានឬទេ? បាទលោកខ្ញុំ

ដេកបាន ចុះលោកសម្រាន្តផ្អៀងម្ខាងទៀតចំនួន ៧ ខែបានឬទេ ? បាទ លោកខ្ញុំដេកបាន ចុះលោកសម្រាន្តផ្កាប់ចំនួន ៧ ខែបានឬទេ ? បាទ លោកខ្ញុំដេកបាន ជីវកកោមារភច្ចឲ្យសេដ្ឋីដេកលើគ្រែចងសេដ្ឋីភ្ជាប់នឹងគ្រែរួចហើយ ក៏វះក្បាលរែកលលាដ៍ចេញ ឆ្កឹះយកសត្វមេរោគល្អិតៗបានពីរចាប់បង្ហាញឲ្យគេមើលប្រាប់ថា ហ៏អ្នកពល់គ្នាមើលចុះសត្វទាំងពីរនេះអា ១ តូចអា ១ ធំ ពួកគ្រូពេទ្យដែលហ៊ានទាយថា នៅតែ ៥ ថ្ងៃទៀតសេដ្ឋីមុខជានឹងស្លាប់នោះ ព្រោះគេបានឃើញសត្វមេរោគធំនេះតែដល់ថ្ងៃគំរប់ ៥ វានឹងជញ្ជក់ស៊ីខួរក្បាលសេដ្ឋីអស់ បានជាសេដ្ឋីស្លាប់ គេទាយដូច្នេះត្រូវហើយមិនខុសទេ ចំណែកពួកគ្រូពេទ្យខ្លះដែលហ៊ានទាយថា នៅតែ ៧ ថ្ងៃទៀតសេដ្ឋីមុខជានឹងស្លាប់នោះ ព្រោះគេបានឃើញសត្វមេរោគតូចនេះ តែដល់ថ្ងៃគំរប់ ៧ វានឹងជញ្ជក់ស៊ីខួរក្បាលសេដ្ឋីអស់ បានជាសេដ្ឋីស្លាប់ គេទាយដូច្នេះត្រូវហើយមិនខុសទេប្រាប់ហើយក៏បិទមុខរបួសរួចដេរថ្នេរភ្ជិតទៅវិញលាបថ្នាំឲ្យ លុះសេដ្ឋីដេកផ្អៀងតែម្ខាងបាន ៧ ថ្ងៃក៏និយាយនឹងជីវកកោមារភច្ចថា លោកគ្រូពេទ្យ ខ្ញុំដេកផ្អៀងតែម្ខាងចំនួន ៧ ខែមិនបានទេ គ្រូពេទ្យសួរថា ក្រែងលោកបានសន្យានឹងខ្ញុំថា សម្រាន្តបាន ៧ ខែមែនទេ ? បាទខ្ញុំបានសន្យាដូច្នោះមែនហើយ តែថាបើលោកបង្ខំឲ្យខ្ញុំដេកផ្អៀងតែម្ខាង ៧ ខែ ខ្ញុំមុខជាស្លាប់មិនខានទេ ។

(មានត)

# កាំពូលកាំសត់

## លោកហាន់-យេង រៀបរៀង

(តទៅ)

ថ្ងៃនិទុក្ខរួចហើយ នាយឧតហាក់ដូចជាបានធូរទ្រូងជាងមុនបន្តិច ហេលភ្នែកតាមមើលពពកទៅ នៅអគ្គយហាលខ្យល់អស់ពេលយូរ បានចូលកាន់ដំណេក ។

មានយប់មួយ ព្រះចន្ទ្ររះត្រចះត្រចង់កណ្ដាលអាកាសបំភ្លឺផ្ទៃលោកឲ្យរីករាយសប្បាយ នាងម៉ាសនិងនាយឧតបាននាំគ្នាចុះទៅជិះទូកលេង នាក់គួចលយកាត់ទឹកក្ដីផ្ទេក ៗ រវេ ៗ ហាក់ដូចជាមានមច្ឆាពណ៌ប្រាក់ហែបហែលលេងជាមួយ សត្វលេខគ្រាំគ្រែងខ្ទិចប្រាំងលាន់ឆ ៗ កុមារកុមារីមានចិត្តត្រេកអរសោទរជងគ្នា ទីធម្មជាតិស្រឡះយ៉ាងត្រចះនាពេលនោះ នៅស្ងៀមតាំងអស់គ្នាមិនមានសាសន៍ថាអ្វី បន្តិចស្រាប់តែក្ដុំខ្យល់យ៉ាងធំលាន់ក្ដុំឡើង ពពកលេខ្មៅបក្សីស្រណោះកន្ធពក្រស្ងាត់ អណ្ដែតតាមខ្យល់សាត់បាត់ទៅឆ្ងាយទៅ នាំឲ្យនាយឧតកើតសង្វេគក្នុងចិត្ត នឹកលើកដល់នាងសាលីដល់មាតាកំសត់របស់ខ្លួន ទើបបោះច្រវាចុះ យកដៃទាំងពីរខ្ទប់មុខខ្សឹកខ្សួលយ៉ាងខ្លាំង នាងម៉ាសកើតស្រឡាំងកាំងក្ដាំងស្មារតី នឹងកិរិយាចំឡែកនៃបងរបស់នាង ទើបនាងស្ទុះមកលួងលោមថា: "បងអើយ! បងយំកើតទុក្ខពុំសុខចិត្តព្រោះហេតុអ្វី បងស្រដីឲ្យប្អូនបានដឹងផង ប្អូនមានទេណា ផ្ញើឲ្យគ្នានឹង

ឲ្យគន្លួលចិត្តបងទេដឹង ប្តីមួយខ្ញុំនេះ បានប្រព្រឹត្តអំពើអ្វី ឲ្យជ្រុល លើបងប្តីដូចម្តេច ! សូមបងប្រាប់ឲ្យប្អូនបានដឹងផង" ។

នាយឧតស្តាប់សំឡេងញ័រ ៗ របស់នាងម៉ាសជាប្អូនហើយ ក៏សន្សឹមងើបមុខឡើង មុខក្រៀមក្រំស្ងួតស្រពោនជោកទៅដោយទឹកភ្នែក ដែលស្រក់ចុះទៅជាដំណក់ភ្លឺថ្លាដូចត្បូងពេជ្រដោយអំណាចរស្មីព្រះចន្ទ តែនាយឧតនៅស្ងៀម គ្រវីក្បាលជាទំនងថា ទុក្ខរបស់ខ្ញុំបងដូចកំទីងប្រាប់ផងពុំបាន តែនាងចេះតែឈ្លបសួរផ្ទួន ៗ យកក្រមាជូតក្បាលជូតទឹកភ្នែកយ៉ាងថ្នមឲ្យបងរបស់នាងពេញចិត្ត នឹងសេចក្តីយល់ចិត្តយល់ថ្លើមរបស់ប្អូន នាយឧតក៏ឆ្លើយថា “ ឱប្អូនអើយ! អ្នកចុះតាំងពីប៉ុន្មានព្រមតាំងរូបប្អូននេះ គ្មានធ្វើអ្វីឲ្យសៅហ្មងដល់ចិត្តផងបងនោះទេ តាំងពីបងបានមកផ្តេកផ្គងក្នុងត្រកូលប្អូននេះ បងបានសេចក្តីសុខគ្រប់ប្រការ ឥតមានប្រាថ្នាចង់បានអ្វីទៀតទេ តែពេលនេះ ឱប្អូនអើយបងនឹកប្រវត្តិដល់ម្តាយរបស់បង ដែលប្រាសឆ្ងាយពីបងទៅចំនួន ៣ ឆ្នាំមកហើយ ខ្ញុំបងតែងតែជាទុក្ខព្រួយ មិនដែលខកខានពេលណាឡើយ ហើយពីខែមុននោះបងបានដំណឹងមកថាម្តាយរបស់បងមានជម្ងឺឈឺជាទម្ងន់ ហើយអ្នកចង់ឃើញមុខបងពន់ពេកណាស់ ពុំដឹងជាបានសះស្បើយទៅហើយឬយ៉ាងណាទេ ហើយបងនៅសប្បាយក្អែកក្អួនតែ

ម្នាក់ឯងដូច្នេះជាការមិនគួរសោះ បានជាបងយំខ្សឹកខ្សួលដូច្នេះ មើលទៅបងចង់សុំលាប្អូនទៅកេមាតាហើយ . . . ។

"ទៅរកមាតា" នាងម៉ាសផ្ទួនពាក្យឡើង ។

នាយឌុតក៏ងក់ក្បាលទទួល ។

"បើដូច្នោះ បងមិនបោលប្អូនឲ្យនៅតែឯងហើយ ! ។

"ប្អូនកុំកើតទុក្ខធ្ងើអ្វី ការទិពសពាកគ្នាជាច្បាប់សម្រាប់ជនទូទៅមិនសំគាល់ថា ឈ្មោះណាជាឈ្មោះណាទេ ខ្លួនបងពុំមានបំណងនឹងឃ្លាតឆ្ងាយពីប្អូនឡើយ តែថាពេលនេះជាកម្មផងបងគោងតែចាកទៅទាំងទុក្ខម្នោម្នញ ដើម្បីនឹងបានជួបមុខអ្នកមេជាទីស្រឡាញ់ ប្អូន ! បងមិនភ្លេចគុណប្អូនទេ ប្អូននៅជាសប្បាយចុះ មើលបំរើមាតាបិតារបស់ប្អូន បើសំណាងយើងមានគង់តែនឹងបានឃើញគ្នាមិនលែងទេ ព្រោះផែនដីនេះមានសណ្ឋានមូល គង់តែនឹងជួបគ្នាបើមិនត្រង់ណេះក៏ត្រង់ណោះ" ។ នាងម៉ាសកាលបើឮពាក្យសំដីដូច្នោះ ក៏ណែនណាន់តាន់តាន់ទ្រូងឥតទំនងពុំកើត ដូចជាមានសភាវៈអ្វីមកបិទបំពង់កជិត មិនដឹងជានឹងគិតយ៉ាងណា ក៏បោកខ្លួនលើស្មានាយឌុតយំសោកជាច្រើន កំឡោះឃើញដូច្នោះក៏ភ្ញាក់ខ្លួនព្រឺត ទឹកញ្ញើមដល់ខ្សែផលបំណងនឹងចងដើររបស់គេឲ្យជាប់នឹងដីព្រាងចំពេះ តែមានចិត្តល្អបរិសុទ្ធណាស់ ទើបយកដៃអង្អែលក្បាលប្អូនលួងលោមឲ្យស្ងប់ស្ងាត់អារម្មណ៍ នាងម៉ាស

កំសន្សឹមៗបាត់យំងើបមុខឡើងមើលមុខបង ហើយញញឹមយ៉ាងផ្អែមល្ហែមត្រជាក់ចិត្ត រួចប្រាសក្បាលទៅវិញ ដាក់ថ្ពាល់សស្អាតផ្ទេកទៅលើទ្រូងនាយឌុត យកដៃស្ទាំអង្អែលស្មាហើយមានវាចាថា " បងអើយ! សូមសន្យានឹងប្អូនថា កុំបោលប្អូនណាបងណា!! ។

នាយឌុតអឹមអៀមនៅស្ងៀមមិនឆ្លើយ ព្រោះពុំច្បាស់គេនាងប្រាថ្នាយ៉ាងណាលើរូបខ្លួន នាងម៉ាស ក៏ក្រោកឡើងចាប់ដៃនាយឌុតទាំងពីរជាប់ហើយ ហោលភ្នែកឲ្យបំភ្នែកបងកំឡោះសាកសួរឡើងទៀតថា "ម៉េចបង និយាយឲ្យប្អូនច្បាស់ក្នុងចិត្តផង?

នាយឌុតពុំដឹងកែប្រែបែបណា ក៏អេះអុះថា "បង....បង..." ។

គ្រោះល្អណាស់ពេលនោះ មានសំឡេងចាស់ៗ ស្រែកហៅមកថា "អឺយ ចៅឌុត! នាំគ្នានិយាយលេងដល់ណាទៀត យប់ជ្រៅណាស់ទៅហើយ អ្នកទាំងពីរភ្ញាក់ព្រើតដកដៃពីគ្នាចេញ នាយឌុតអរលើសលន់យកដៃទាញច្រវ៉ាប្រញាប់វិលមកផ្ទះវិញ ឲ្យផុតពីសេចក្ដីសួររបស់នាងម៉ាស ។

យប់នោះឯងនាយឌុតដេកមិនលក់សោះ សេចក្ដីនឹករត់ទៅរកមាតាក៏ឧប្បត្តិឡើងក្នុងខួរក្បាលរបស់គេ ទើបគិតគ្រាន់តែរវេចសំពត់អាវស្រេច លបស្ដាប់មើលក្ដិនភាគអ្នកផ្ទះ គេដេកស្ងប់ស្ងាត់ហើយឬនៅក៏ឮសូរតែសំឡេងតុកកែនឹងចចកងរំពង ទឹងសព្ទសូរស្រមុក ទើបនាយឌុត

ទាញយកក្រដាសខៅដៃ  សរសេរសំបុត្រទុកចោលនឹងដំណេកខ្លួន ដើម្បីនឹងឲ្យអ្នកផ្ទះនោះដឹងដើមហេតុ  រួចហើយក៏ម្នីម្នាចុះចេញពីផ្ទះទៅ ដើរយ៉ាងថ្នមជើង  ចេញផុតភូមិកាលណា  ក៏រត់តែម្ដងនាំឲ្យឆ្កែផ្អើល ព្រុសលាន់  ទើបនាយឧតឈប់ងាកមើលក្រោយខ្លាចក្រែងគេភ្ញាក់តាម ដើររត់ទៅទៀតបោះជើងយ៉ាងវែងៗ ។

## បទទី ១៦

## វិទ្យាល័យ ស៊ីសុវត្ថិ

លុះដល់ម៉ោង៤គត់  ស្គរសាលាក៏លាន់ឮខ្ទរៗឡើង  ក៏ជាហេតុ ញ៉ាំងចិត្តអ្នករៀនឲ្យរីករាយគ្រប់គ្នា  កាលបើពួកសិស្សជាន់មធ្យមចុះ មកដល់ថ្នាក់ក្រោម  ស្រាប់តែព្រះពិរុណហែកមេឃធ្លាក់ចុះមកលើប្រឹប ពីលាន់ខ្ទរៗ គ្រាប់ភ្លៀងធំៗ ជ្រះលើស្លឹកឈើខៀវស្រងាត់  ដែលរលាស់ ឲ្យធ្លាក់ចេញជាលំអងទៅក្រោម  មានជាទឹកហូរបន្តគ្នាពីជាយដម្បូល មកធ្លាក់ដល់ព្រះធរណីរលាយដីឲ្យរលាយដូចជាស្ករ  រួចផ្គុំគ្នាជាខ្សែទឹក ហូរទៅឆ្ងាយ  កាលបើត្រូវទឹកធ្លាក់ពីលើមក  ក៏ឮសូរឫកធ្លាក់ៗ ដដែលៗ គួរឲ្យស្រនេះស្រណោច  អ្នកទាំងអស់គ្នាក៏លាន់មាត់ឡើងដោយសេចក្ដី ថ្នាក់ចិត្តព្រោះជ្រៀតត្រូវឈរចាំអស់ពេលយូរហើយពោះក៏ឃ្លានផង  ខ្លះ អត់ព្រាំពុំបានក៏ដោះអាវដាក់ក្នុងក្រប៉ូច  ហើយជិះកង់ដំរង់ទៅរកអាហារ ដែលត្រៀមចាំឯផ្ទះ  ដែលសាយក្លិនមកដល់ទប់ទល់ពុំបាន ។

លើចិញ្ចើមឥដ្ឋ កុមារីបារាំងម្នាក់ដើរមួយ ៗ ត្រង់ភ្លើង ចំមុខ ព្រងើយមិនរវល់នឹងភ្លៀងសាចមកត្រូវ នាងមួយទៀតពាក់អាវភ្លៀង ពណ៌ខ្មៅរត់កាត់វាលសាលាចុះឡើង រលាស់សក់ក្បាលទៅក្រោយ ព្រមដោយលំអគួរឲ្យគន់ មានដំណក់ទឹកស្រក់តក់ ៗ មកពីលើមុខស្អាត ។ នៅក្នុងហាងលក់ពួកសិស្សនៅក្នុងសាលា នាំគ្នាអ៊ូអរលេង បាល់ជាសប្បាយនៅក្រោមកន្ទេងដែក អ្នកឯទៀត ៗ នាំគ្នាប្រជុំនិយាយ ពីនេះពីនោះគ្រាន់កំសាន្តចិត្ត ។

នៅមុខថ្នាក់រៀនជាន់ក្រោម បែកក្លាងក្បែង ពួកកុមារ ៦ នាក់ ឈរនិយាយគ្នាលេង នាងមួយខ្ពស់ចង្រ្គាំងខ្នងកោងបន្តិច ឈ្មោះនាងសម្ពមណី មានសំលេងស្រួយស្រស់ដូចផ្ការដើមរ៉ក មួយទៀត គឺនាងទិលឡា ពងតាបមុខមូលភ្លែកស្អាប់សំលេងញ៉ាវ ៗ សើចមិនឈប់ ឯនាងសារ៉ុត មុខផែនស្គមតូចស្ដើងរហ័សខាងភ្នាក់វិស័យដូចសត្វកំប្រុកតមក ដល់គូមេត្រីមេសុខពីរនាក់ មួយនោះ មានរូបរាងធាត់កន្ត្រៀមុខធំ ថ្ពាល់ត្រយល់ មាត់មានរង្វះវែង ភ្នែកតូចពព្រិមលិបបាត់ទៅ កាលបើនាងសើច នាងនេះហាក់ដូចជារូបតុក្កតាបេះដើងដូងប្រុះឯង នាងមានឈ្មោះថាមាក់ខ្ញែរ តែអ្នកផងហៅថា "អ្នកស្រីប៉េងហ៊ុង" ចំណែក គូមេត្រីរបស់នាងនោះ រាងតូចទន់ខ្ចីដូចដើមត្រែង មុខមាត់ប្រិមប្រិយ៍ មូលក្រឡង់ល្អគ្មានខ្ចោះត្រង់ណា នាងញញឹមឡើងកាលណាកក្រៅ

ផុសផង់បំព្រងះឡើងដុះស្មើនៃវ័យក្មេង នារីនេះឈ្មោះផលា តែគេតែងហៅថា "ផ្កាយព្រឹក" ដោយនាងជាសេចក្ដីសប្បាយនៃចាក់របស់នាង ក្រោយបំផុតបានដល់មកនាងបុប្ផាសួគ៌ ជាកុមារីគប់លក្ខណ កិរិយាស្រគត់ស្រគំ មាត់ក្រប៉ូវភ្នែកធំក្រឡេតចិញ្ចើមស្ដើងមាសទឹងដំណើរដើរទ្រន់ដូចឃ្លោងបន្តិច ។

នៅជិតនោះ មានកុមារពីរនាក់កំពុងដៃគ្នាលេង កុមារមួយមុខស្រពោនពុំសូវស្ដីនិយាយ យកដៃផ្អែកលើក្បាក់បង្អួចចាំស្ដាប់ នាយលុន-ហាក់អធិប្បាយសេចក្ដី កុមារទីពីរនោះមានខ្លាមធំ ច្រមុះស្រួចភ្នែកធំ សក់ញ៉េកចំពាក់កណ្ដាលក្បាល កំពុងតែនិយាយប៉ប៉ាច់ផ្ទាត់មេដៃផ្សំផង រួចសើចកងឡើងបញ្ចេញធ្មេញឈើព្រាង ដែលបបូរមាត់ក្រាស់បិទមិនជិត ហើយក៏បង្កិលខ្លួនដូចព្រាបលើដំបូលផ្ទះ តែអ្នកទាំងពីរនោះ ច្រើនអាក់សេចក្ដីសន្ទនាដោយសំណើចយ៉ាំងទ្រាន់នៃកុមារទាំង២នាក់ លុខ-ហាក់ក៏បាត់មាត់ស្ងៀម គូកនរបស់គេក៏មិចភ្នែកឲ្យនិយាយតទៅទៀត រួចខ្ទងលាន់សំដីឡើងថា "លុន - ហាក់ឯងកុំហាមាត់សើចខ្លាំងពេក លេចកូនមេញហើយ កូនមេញអីល្អម៉្លេះហ្ន៎ ! ។

ក្នុងវេលានោះ បុប្ផាសួគ៌ទប់ទឹកលែងសើចធ្វើមុខក្រញូវ ចងចិញ្ចើមរកគ្នា បាញ់ភ្នែកសំឡក់មកស្មើទិងក្តាក់សាប ។

“ទុនេះខ្ញុំឥឡូវហើយ គុណព្រះជួយ” បុរសដដែលពោលឡើង ដោយយកដៃបាំងមុខ “នេះបានចំជាអគ្គិទេក្រ កុំថាឡើយត្រឹមថ្មឬដែក សូម្បីតែភ្នំព្រះសុមេរុក៏រលាយដែរ” ។

នៅពេលនោះ បុប្ផាសួគ៌អត់ពុំបានក៏ប៉ាត់ញ៉ាត់ដំរង់មក ព្រមដោយកុមារីឯទៀត ៗ ផង មុខនាងឡើងក្រហមឆេះដូចបង្កងដុត នាំឲ្យលុន-ហាក់រត់ឲ្យរួចខ្លួនបាត់ទៅ នៅសល់តែកុមារមុខស្រពោននោះឯង នៅកណ្ដាលចំណោមកុមារីទាំង ៦ នាក់ បុប្ផាសួគ៌សួរឡើងថា “បងនិយាយឲ្យអ្នកណាអម្បាញ់មិញនេះ ថាសើចចេញកូនធ្មេញ?

“បាទ ខ្ញុំថាឲ្យលុន-ហាក់ ជំពប់ប្រសាសន៍អ្នក តើមានប៉ះពាល់ដល់រូបអ្នកដែរឬអ្វី?

“ចាះប៉ះដែរ ព្រោះខ្ញុំមិនមែនកូនក្មេងបៅដៃកាលណា ចាំបងថាយ៉ាងនេះអី បងដឹងថាខ្ញុំអកុសលមានធ្មេញតូចដុះដើងធ្មេញដែរ ម្ដេចក៏ចិត្តអាក្រក់បន្តុះបង្អាប់ដូច្នេះ?

“ឱ! អ្នកមានកូនធ្មេញឬអ្វី? ខ្ញុំមិនដឹងសោះ ។

“ចាំតើអី”

“មិនតើទេជំពប់ប្រសាសន៍ ខ្ញុំបាទមិនដឹងពិតណា តែតាមសំ-ឡេក គេថានាងណាមានកូនធ្មេញនោះប្រិយសីណាស់ ទើបបានជាលោកជំតាមិនខានទេ រូបអ្នកនេះទើបមានសំណាងមិនខាន ។

នារីទាំង ៤ នាក់ក៏សើចគិលឡើង ធ្វើឲ្យទោសៈនាងបុប្ផាសួគ៌ប្រឡែតភ្លាំងឡើង ខាំបបូរមាត់ជាលឈាមធ្វើក្អកម៉ក់ៗ ស្រាប់ពេលនោះរន្ទះអសុរទ៍បាញ់ឆាំងមក កុមារបោនមាត់ថា "នេះឃ្មានចំណាររន្ទះទាំងប្រាំពីរជាន់ ក្តុកអស់ហើយព្រៃព្រឹក្សា ខ្ញុំស្ទើរតាំងស្មារតីបាត់ព្រលឹងព្រលះអស់ ចុះអ្នកខាងណោះមិនភ័យទេឬអ្វី បើរងំយ៉ាងនេះ?"

បុប្ផាសួគ៌ឮពាក្យបំអកដល់ខ្លួនដូច្នោះ ក៏ខឹងណាស់ស្រក់ទឹកភ្នែកតទ្រំដើង មាត់ផ្ញើរដើរចេញពីនោះទៅ ព្រមទាំងនាង ៣ នាក់ទៀត នោះបល់តែផ្កាយព្រឹកខឹងគួកប៉េង ហុង ផ្កាយព្រឹកលាន់មាត់ថា : "ម្ដេចក៏គ្របបាត់ភ្លៀងអីម្ល៉េះហ្ន៎! ហៅសែនរំខានអស់យ៉ាងហើយ ចុះបងគិតដូចខ្ញុំដែរឬអ្វី មិនអញ្ជើញទេឬ មេឃទូរទ័មយ៉ាងនេះ? មួយវិញទៀតឃ្លានបាយទេ ថ្ងៃល្ងាចណាស់ទៅហើយ ?

"ទេ! ខ្លួនខ្ញុំនេះហាក់ដូចជាពួកទេវតាដែរ មិនចេះឃ្លានបាយឃ្លានទឹកទេ គ្រាន់តែហិតអាហារទិព្វនោះក៏ឆ្អែតទៅហើយ បើបានតែប្អូននៅជាមួយផងនោះ ទុកជាភ្លៀងដល់យប់ក៏ពុំឃ្លានដែរ ។

ខ្យល់រំភើយៗ បក់បូលមកប៉ះសក់ផ្កាយព្រឹកដែលលលកទៅក្រោយ មុខនាងក៏ឡើងពណ៌ស៊ុជម្ពូយ៉ាងស្រស់ ដល់បានឮសំដីបុរសថាដូច្នោះនាងឆឹកអៀនខុនមុខចុះ ម៉ាក់ឡៃក៏យកគួយដៃគោះគូកនរបស់

នាងផ្កាយព្រឹកប្រែទៅរក "មិនដឹងជាទឹងគោះអ៊ីចឹង ហៅផិនអស់យ៉ាងហើយ" ។

រួចក៏នាំគ្នាសើចឡើង ផ្កាយព្រឹកនិយាយទៀតថា "ហៅស្ដាយអស់យ៉ាងហើយ បុប្ផាសួគ៌ទៅបាត់ បានអ្នកណាគ្រាន់តែអផ្សុកអេះ មើលចុះមុខកាន់តែស្រពោនទៅហើយ ។ ឱពុទ្ធោអើយ! គួរអាណិតណាស់ហ្ន៎!

រួចក៏ពោលកន្ទុយភ្នែកមើលបុរសនោះ កុមារីទាំងពីរនាក់ញញឹមរកគ្នារួច ក៏នាំគ្នាដើរចេញទៅបាត់ទៅ ទុកឲ្យអ្នកនោះនៅតែម្នាក់ឯង ។

ភ្ញៀវក៏នៅតែធ្លាក់ខ្លោក ៗ មកនៅឡើយ អាកាសក៏ងងឹតចុះព្រោះចូលសន្ធ្យារាត្រីទៅហើយ ត្រូវខ្យល់ត្រជាក់បក់មកត្រូវកុមារៈនោះ នាំឲ្យទឹកឃ្លានបាយកាន់តែខ្លាំង ទើបកាត់ចិត្តចេញពីសាលាដើរហាលភ្ញៀវរងាញាក់ត្រទ ៗ ដល់ផ្លូវហើយក៏ឡើងជិះត្រីចក្រយានដម្រង់ទៅផ្ទះអាត្មា កាលបើដល់កន្លែងហើយ ក៏តាំងចាប់ផ្ដើមបរិភោគអាហាររួចដើរចុះឡើងចំនួនកន្ទុះម៉ោង ទើបទាញកៅអីអង្គុយនៅមុខតុ ទាញដងប៉ាកកានិងក្រដាសមក អង្គុយជញ្ជឹងគិតមួយស្របក់ ទើបសរសេរសេចក្ដីដូចមានខាងក្រោមនេះ

ភ្នំពេញថ្ងៃ ១៥ អុកតូប្រ៍ ១៩៣៧

# មកដល់សាលីប្អូនសំឡាញ់!

ប្អូនអើយភ្លៀងទើបនឹងដាច់គ្រាប់ មេឃក៏ស្រឡះប្រាសចាកមន្ទិល ព្រះចន្ទ្ររះចំពៀងត្រោងត្រាតរស្មីលើផ្ទៃទឹកទន្លេ ធ្វើឲ្យបងស្រណោះនឹកដល់ពេលដែលយើងអង្គុយលេងនៅមាត់ទឹក ទើបបងភ្ញាក់ខ្លួនព្រើតចាំបានថា ខានផ្ញើសំបុត្រឲ្យដំណឹងមកសាលីប្អូនរបស់បងជាយូរណាស់មកហើយ សមជាប្អូនទន្ទឹងសង្ឃឹមណាស់ហើយមើលទៅ យប់នេះបងមានពេលទំនេរច្រើន បងបានចាប់ដងប៉ាកកាដោយសេចក្ដីត្រេកអរសរសេរក្រោមពន្លឺព្រះចន្ទ្រ ។

កាលបងផុតពីកណ្ដាប់ដៃនាវីបាម បងបានមកសំណាក់ផ្ទះម្ដាយមីង ហើយគាត់បានបញ្ចើមបងឲ្យរៀនសូត្រតទៅទៀតឯសាលាឈ្នួល ថ្ងៃមួយ បងតាច់លើចិញ្ចើមផ្លូវ "កេពីកេត់" ស្រាប់តែឃើញស្ត្រីកណ្ដាលអាយុចេញពីផ្ទះភាត់ទោអាវមក រួចស្ទុះមកឱបបងតែម្ដង បងភ្ញាក់ព្រើតងាកមើលទៅ ស្រាប់តែដឹងថាជាអ្នកម្ដាយរបស់បង ឱប្អូនអើយ! រកអ្វីឲ្យសប្បាយយ៉ាងហោះហើរដូចៗនឹងជួបមុខម្ដាយនឹងកូនក្រោយពេលដែលឃ្លាតឆ្ងាយមកជាយូរនេះគ្មានទេ! សេចក្ដីមេត្រីដែលបងបានបៀមទុកក្នុងដើមទ្រូង អស់កំឡុង ៣ ឆ្នាំមកហើយ ក៏ផុះស្រោចស្រប់ទៅលើដើមទ្រូងមាតារបស់បង បងក៏រឹតអ្នកយ៉ាងខ្លាំង ក្រែងអ្នកឃ្លាតចេញពីបងទៅទៀតបាន ។

ជាប់តាំងពីថ្ងៃនោះមក បងលែងនៅផ្ទះម្ដាយមីងទៀតហើយ ជញ្ជូនខោអាវទៅនៅជាមួយនឹងម្ដាយរបស់បង ផ្ទះនោះធំស្រឡះល្អណាស់មានសួនច្បារពីមុខមានវាលសម្រាប់លេងកូនគី ដល់ប្អូនមកលេងស្រុកភ្នំពេញជាន់ក្រោយទៀតនោះបងនឹងបានទទួលប្អូនយ៉ាងគួរបំផុត ម្ដាយរបស់បងស្រឡាញ់ប្អូនខ្លាំងណាស់ ហើយមានប្រាថ្នាតែនឹងជួបឃើញប្អូនប៉ុណ្ណោះ រាល់តែថ្ងៃយើងជំនុំគ្នានិយាយតែអំពីប្អូនប៉ុណ្ណោះ ។

សព្វថ្ងៃនេះ បងបានចូលរៀនក្នុងវិទ្យាល័យស៊ីសុវត្ថិហើយ ថ្ងៃចូលដំបូងកាលបើបងដើរហួសមន្ទីរអាបារ្យធំបន្តិចទៅ ក៏កើតការភាំងភិតវង់ នៅមុខគុក ពីរជាន់នឹងដើមឈើមកពីប្រទេសក្រៅមានស្លឹកខៀវស្រងាត់ ដុះជាជួរនៅផ្លូវលេង

ធ្វើឲ្យមានទម្ងប់សប្បាយ លុះបងឈានជើងចូលក្នុងកន្លែងរៀនហើយក៏ភ្ញាក់ខ្លួនព្រឺត ដោយឃើញកុមារីទាំងយួនទាំងខ្មែរចំនួន ១០ នាក់ លាយឡំនឹងអស់ពួកក្រុមកុមារ បងក៏អត់មិនបានឈ្លាន់មាត់ថា "ប៉ៃ! មានពួកស្រីៗជាមួយនឹងយើងផង" បណ្ដាអ្នករៀនដូចគ្នា បងពុំស្គាល់អ្នកណាមួយឡើយ ហើយមានម្នាក់ដូចជារួស រាយគួរសម ៗ ចំណែកឯពួកអាចារ្យបង្រៀនទាំងប៉ុន្មាន ក៏មានអធ្យាស្រ័យរីក រាយរាក់ទាក់ស្រួលល្អ តែសុទ្ធតែជាជាតិយួនទាំងអស់ នាំឲ្យបងនឹកអន់ចិត្តជា ច្រើនដោយគិតថា "ដូចម្ដេចហ្ន៎! បានជាជាតិខេមរៈយើងមិនចូលចិត្តធ្វើគ្រូសោះ បណ្ដោយឲ្យជាតិដទៃគ្រប់គ្រងសាសន៍ឯងទៅវិញ" ។ បងចូលរៀនបានមួយខែ មកហើយពុំមានទាស់អធ្យាស្រ័យអ្វីនឹងអ្នករៀនដូចគ្នាទេ ចំណែកពួកនារីក៏ស្រួល ណាស់ដែរក្រៅអំពីបុប្ផាសួគ៌ ដែលខ្ចិចខ្ចក់ច្រើនបន្តិច ។

បងសូមលាប្អូនត្រឹមណេះ បានលើកក្រោយនឹងសរសេរឲ្យវែងជាងនេះទៅ ទៀត ព្រោះបងពុំមានពេលទំនេរច្រើនទេ សូមប្អូនអត់ទោសដល់បងចុះ ។

បាកសុភិន្ទ្រ

ចំណែកនាងសុភិន្ទ្រក៏បានសេចក្ដីសុខជាបឋមគេ រៀនក៏ពូកែបាន ឡើងថ្នាក់ជាលំដាប់ មានមិត្រគប់រកជាច្រើន អាចារ្យទាំងប៉ុន្មានក៏ពេញ ចិត្តនឹងកុមារគ្រប់គ្នា ពល់តែខែអ្នកតែងបានកិត្តិយសបត្រអំពីសំណាក់ អាចារ្យធំផលដាច់ឆ្នាំក៏បានរង្វាន់ពុំដែលខានរហូតដល់ថ្នាក់ទី ៤ ក៏ប្រឡង ឌីប្លូមជាប់ រួចអ្នករៀនយកចំណេះបាស្សទៀត តែងខំប្រឹងប្រែងមិន ដែលឲ្យខូចពេលវេលា ដោយការដើរលេងឥតប្រយោជន៍សោះឡើយ រហូតដល់បានសម្រេចប្រយោជន៍ យ៉ាងជាន់ខ្ពស់បណ្ដាច់ពីរជាន់ទៀត គឺបាស្ស ។

(មានត)

បណ្ដៅ

# ឃុនឧត្តមប្រីជា ពាប - ពិន

រួបរួមនឹងរៀបរៀង (តមកនឹងចប់)

| បណ្ដៅ | ដោះស្រាយ |
|---|---|
| ១០៨ - ដើរទៅប៉ាត់ញ៉ាត់ ដល់ទៅព្រែស្វាត់ ឆ្អឹមុខ ដូរញ៉ូញ? . . . . . . . . . . . . . . . . . | ដុះ |
| ១០៩ - អង្គុយមួយកំប៉ុក សក់ស្រកពេមភ្ញី? . . . | អាចម៍ |
| ១១០ - ខ្សែមួយចង្វាយកយគ្រប់ស្រុក? . . . . . . | ផ្លូវ |
| ១១១ - ទុកពេលចាស់ ប្រើណាស់ថ្មី? . . . . . | ផ្លូវ |
| ១១២ - លាដមួយកំព្រែង វែងគ្រប់ស្រុក? . . . | ផ្កាយ |
| ១១៣ - ដូងមួយពណ៌ត ចិតទៅលើមេឃ? . . . . . | ខែ (ព្រះចន្ទ) |
| ១១៤ - ចាំងមួយថ្ងៃពាលល្ងាច កេរ៍កាច់គ្មាន? . . | ថ្ងៃ |
| ១១៥ - វេញកន្ទុះ ទុកខ្ទុះអាញ៉ាញ? . . . . . . . | បេសម្លុល |
| ១១៦ - ត្រប់ខ្សែខ្លាញ់ សំឡៀងឲ្យពំ ទាងអោយសម្ងំ បង់ផ្សាំងត្លួទឲ្យ? . . . . . . . . . . . | ដោតត្លុទម្លុល |
| ១១៧ - វេញពួរទៅក្លួសគល់ គិតមិនយល់ផល់ក្លួសពួរ? | បេសម្លុល |
| ១១៨ - លតានាមជាសុវណ្ណ តែងដុះពន្ធពន្ធ លើដើមព្រឹក្សា? . . . . . . . . . . . . . . . . | វល្លិមាស |

| បណ្តៅ | ដោះស្រាយ |
| --- | --- |
| ១១៩ – ក្រោលតាព័ទ្ធបុង មច្ចាពូនកង ពូនប្រែបអគ្គី? | ដំបុតត្រី |
| ១២០ – ទឹកមួយថ្លុក ពស់ពេនអើតក? . . . . . . . | បង្កៀងខ្លាញ់ |
| ១២១ – កំប៉េងកំពោះ កំប៉េងឥតដោះ កំប៉ោះកូនប្រើន ចិញ្ចឹមកូនរស់? . . . . . . . . . . . . | មេមាន់ |
| ១២២ – ប្រាប់កលៀនអណ្តាត? . . . . . . . . . | ក្អមទឹក |
| ១២៣ – គ្រលេងគ្រលោងលោក អ្នកណាទោតរកមិនឃើញ? . . . . . . . . . . . . . . | សត្វត្រលេង<br>ត្រលោង |
| ១២៤ – គោក្រហមលិទ្ធកុតគោខ្មៅ? . . . . . . . | ភ្លើងនឹងឆ្នាំង |
| ១២៥ – អស់ទាំងគេដើរតាមផ្លូវ អាមួយតូរម៉ូរ ដើរតែកន្ទៃព្រៃ? . . . . . . . . . . . . . . | ស្រមោល |
| ១២៦ – ដាក់ទ្រលើចុងឫស្សី មិនត្រូវត្រី ត្រូវទាំងកំប្លង់? | ពោមពោះ |
| ១២៧ – ហាលស្រូវលើចុងរកា អ្នកគ្មានប្រាជ្ញាសា ស្រូវមិនអស់? . . . . . . . . . . . . . . | ខែលសាស្ត្រា |
| ១២៨ – ខ្ទិកខ្ទុកដកឡើងក្រហមទុំ? . . . . . . . | អក្ខុលទុំ |
| ១២៩ – កំប៉ាតដូចស្លឹកម្លូ ប្រហោងក្រហូ មមិសជុក? | ស្លឹកត្រចៀកពោ |
| ១៣០ – កំប៉ាតៗ កំពាងៗ ព្រឹកព្រហាម បញ្ចាក់ស្រើៗ? | បង្គើរ |

| បណ្ដៅ | ដោះស្រាយ |
|---|---|
| ១៣១ – នាងរុំបនាងវៀរ ចង្កេះនាងវៀរ នាងអុំទូកលេង នាងផ្លាត់តាប៉ុ នាងក់យដាក្រូង នាងអុំទូកលេង កណ្ដាលអាកាស ? . . . . . . . . . . . | ខ្លែងឃ្លុង |
| ១៣២ · អស់ទាំងគេផើមចេញពីពោះ ប៉ុន្តែនាងមួយ នោះ ផើមចេញពីក្បាល? . . . . . . . . . . | ដើមចេក |
| ១៣៣ – ខ្ញុំកើតឡើងព្រួបនិងខ្ញុំប្រាប់ ថាម្ដាយខ្ញុំស្លាប់តាំង ពីខ្ញុំមិនទាន់កើត[១]? . . . . . . . . . . . | ដើមចេក |
| ១៣៤ – កូកកូរ កូកចុះទៅ កូរឡើងលើ ក្រឡេកមើល ទៅ ដូចដើងក្រពើ កូរឡើងលើ កូកចុះក្រោម? | ស្លឹកចេក |
| ១៣៥ – អស់ទាំងគេកស៊ីនៅដី អាសង់កខ្ញុំកស៊ីលើផ្ទះ? | សង្កើច |
| ១៣៦ – សេះគេស្អប់ ឆាប់គេថើប? . . . . . . . . . | សង្កើច |
| ១៣៧ – ទឹកមួយថូក កំពឹសពាំងពេញ? . . . . . . . | ផ្លែក្រូច |
| ១៣៨ – ហៅអ្នកបង្រៀន ឃើញសត្វបង់ដើង ឃើងផងប្ត ទេ សត្វលាក់ក្រចក វាយកទៅស៊ី ត្រង់ត្រង់ ព្រះមេ ក្រោមដើមលាក់ផ្កា? . . . . . . . | លោកសង្ឃ, ដំរី, មាន់, ឆ្មា, ស្រែ, ដើមល្ហុ |

១ ន័យមួយថា ផឹករំលុងផើកពាំ ? ។

បណ្ដៅ | ដោះស្រាយ

១៣៩ – ឈើខ្លឹមនៅដីគេកាត់ បែកជាកំណាត់ បែងជា
ផ្លែងបួន ស្រេចហើយគេសាង ជារូបស្រីសួន
ហើយគេបំពាន ទៅនាឋានផ្លង់ ហៅលម្អូនទឹម
នួនរហង់ ត្រមោចឯកអង្គ កណ្ដែងកណ្ដោច
អាសូរស្រីតូចៗ ពុំដឹងតំណូច អាណោច
អាថ៌ម ហេតុកម្មពាំព្រេងនាយនាំ មកឲ្យរងកម្ម
រង្គួយតែស្រី? . . . . . . . . . . . . . . . ដូនពៃសំណែន

១៤០ – អង្កាមស្រមាមអស់អង្គ កំកៀបផ្ការផង់ កំដៃឡើង
ស្រី ប្រមុះទៅញាល់ទឹងដី កំដៃឡើងស្រី កំ-
កៀបៗ បង? . . . . . . . . . . . . . . . ដំបែបិទស្រា

១៤១ – កកីបីបោះ កកោះបោះផាង កញ្ចប់ចាងណាង
ប៉ោកប៉ុកស្រឡេត? . . . . . . . . . . . . . . កី

១៤២ – ប៉ុកខ្វិកប៉ុកខ្វេក ដំដែងដើងបើកចាក់ហោះរន្ធស្រាប់
ទន្ទិចម៉ាប់ៗ ចេញទឹកសើមៗ? . . . . . . ត្បាញសំពត់

១៤៣ – ញ៉ែៗ ញ៉ាចៗ កាន់រំពាត់មួយបាច់ លេងក្មេង
កាច់កែ ចាស់ហើយមិនគិតអៀនគេ លេងក្មេង
កាច់កែ ទាំងព្រឹកព្រហាម? . . . . . . . . ផ្ដិចកប្បាស

| មេណ្ដាំ | ដោះស្រាយ |
| --- | --- |
| ១៨៤ - ព្រហាម់ស្រោងស្រេច កាន់ពាត់មួយបាច់ទៅរក<br>ក៏យកគេ  ចាស់ហើយមិនគិតខ្មាសគេ  ទៅរក<br>ក៏យកគេរេកាំពេន ? . . . . . . . . . . | ផ្ដួចកប្បាស |
| ១៨៥ - កំងអើយកំងរេកំងដុះកណ្ដាលទន្លេ គេហៅកំងអី? | ព្រិល |
| ១៨៦ - ស្រីសល្អបីដង ដល់ចាស់កោងខ្នងស្រីល្អម្ដងទៀត? | ស្រូវ |
| ១៨៧ - លើកបីត្រកង ព្រលឹងមាសបង បីដងហើយដាក់? | ច្រូតស្រូវ, ចងកណ្ដាប់ |
| ១៨៨ - ចង់ជោមប្រឡោមព្រោះទៅ  កណ្ដាលទឹកជ្រៅ រេ<br>កចាំរង់ ដងវែងប្រវែងដៃកាន់ ចាប់ជាកំណាន់<br>ដូចគេសំពះ  ទាំងប្រាំទៅនាំចង្រៃ  សាមសិប<br>នៅកាយ  បើកទ្វាររង់ចាំ ? . . . . . . . . | ប៉ែនធ្វើនំ បញ្ចុក |
| ១៨៩ - ប៉េលប៉ាលហាលស្លាប    ជើងតាបលាបម្រ័ក្ស<br>ជើងបាក់ចាក់ទ្រូស ? . . . . . . . . . . | តាំងយូ |
| ១៩០ - បក្សីបក្សាសត្វ  ខ្ទួនហើរទៅបាត់ ទុកតែជើងនៅ ? | ជើងជើងចាប |
| ១៩១ - ទាញល្ងើមួយញួយកល់មែក ? . . . . . . . | រហាត់វៃ |
| ១៩២ - អាសដាក់លើអាខែកក្រែក    ទាញហើយរឹតតែ<br>ស្រែក  ស្រែកហើយរឹតតែទាញ ? . . . . . . | កូរអម្បោះ |

| បណ្ដៅ | ដោះស្រាយ |
|---|---|
| ១៥៣ - ប្រស់អីយប្រស់ប្រួល ប្រស់ដុះកណ្ដាលទ្រួល គេហៅប្រស់អី? . . . . . . . . . . . . . . | ប្រស់ស្វា |
| ១៥៤ - ព្រអីយព្រព្រឹង ព្រដុះកណ្ដាលបឹង គេហៅព្រអី? | ព្រលិត |
| ១៥៥ - ចាប់កន្ទុយស្រែកហៅ លេបអាចម៍មួយស្រែ តែមិនស្អុយ? . . . . . . . . . . . . . . . . . | ហ្វូកផ្ដើ |
| ១៥៦ - អង្គុយម៉ះៗ ធ្ងះអាចម៍មាន់? . . . . . . . . . . | ឆ្កៀសបន្ទុះ |
| ១៥៧ - ជើងបី ក្បែកបួន? . . . . . . . . . . . . . . | មនុស្សចាស់ ដែលកាន់ ឈើច្រត់ ពាក់វ៉ែនតា |
| ១៥៨ - ក្រហមចុង ស្ញឹញក្នុង លើងក្រៅ? . . . . . | បារី |
| ១៥៩ - ស៊ីមិនឆ្អែត អត់មិនស្គម? . . . . . . . . . | ដក់ញុំ |
| ១៦០ - ដីមួយដុំ ជុំនុំគ្នាស៊ី? . . . . . . . . . . . . | អើបស្វា |
| ១៦១ - មាន់តិលបង្អិលលើផ្ទះ ក្មេងច្រើនលើកដៃសំពះ ទទួលមាន់តិល? . . . . . . . . . . . . | ហិបស្វា |
| ១៦២ - អាក្រឡិតបុកក្ដិតមេសមែង ដកឡើងក្រហមតែង យកអណ្ដាតលិទ្ធបង? . . . . . . . | ត្បាលបុកស្វា |

| បណ្ដៅ | ដោះស្រាយ |
|---|---|
| ១៦៣ – កំប៉ុតពីក្រោម មួយពង្រោមពីលើ សង្កត់ ក្បាលផើងឆើ តើគេហៅអី? . . . . . . . . . | ឈ្នក់ជាប់ត្រី |
| ១៦៤ – ស្រុកមួយមានតែឈ្មោះ ពល់រូបទាំងអស់ទៅ ហើយមិនមក? . . . . . . . . . . . . . | ស្រុកខ្មោច<br>ព្រៃខ្មោច |
| ១៦៥ – ពុំតែមាត់យំ មិនដែលឃើញរូប? . . . . . | ផ្គរ |
| ១៦៦ – អ្នកអើយមើលលើ មើលសត្វក្រពើពងលើ ចុងគ្នាត? . . . . . . . . . . . . . . . | ទៅគំពុងក្រពើ |
| ១៦៧ – ទាញដើមវល្លិ៍រើក រពើកវល្លិ៍រាយ ទាញដើមដក់ ពាយ កញ្ចន្ទារី កំប្រុកក្បាលពារ កន្ទ្រើខក្បាល ប្រាំ ពុំផ្គរដើមធ្នាំ កន្ទុយព្រែត១? . . . . . | ស្លាបបាច<br>ទឹកស្រែ |
| ១៦៨ – អង្គឯកចំខ្សែតជាង៖គ កូនមិនដូចមេ មេមិនដូច កូនគេចាប់កូនចង់ គេយកកូនទៅ ទុកមេឲ្យនៅ រក្សាទ្រព្យគេ? . . . . . . . . . . . . . . | កូនសោ |
| ១៦៩ – នាងអីនាងអើត អង្គុយបន្ទត់ អើតលិច១? . . | ផ្ញិញហាន់ថ្នាំ |
| ១៧០ – ពីតូចស្លៀកសំពត់ ធំឡើងមិនបេះវត់ ស្រាត សំពត់ដួតក្បាល? . . . . . . . . . . . . . . | ផ្លែត្រប់ |

បណ្ដៅ ដោះស្រាយ

១៧១- សសូលបណ្ដូលគុជ ក្រហមចុង សំទឹកតល់? ទៀន

១៧២- កំប៉ុកកំប៉ូវ អង្គុយកណ្ដាលផ្លូវ ពាក់អាវព្រៃឡោ គីង្គក់

១៧៣- ចាស់ហៅឪ ក្មេងហៅឪ ស្ដេចពីម៉ែពីឪ ក៏ហៅឪទាំងអស់? . . . . . . . . . . . ឪឡឹក, ឪឡូ, ឪឡោក។ល។

១៧៤- គោដេក ខ្សែដើរ? . . . . . . . . . ឪឡឹក, ត្រសក់

១៧៥- អាធូរអាធាត់ អាធូរអត់មាត់ អាធូរធាត់ឯង? . . . ទ្ទើយ

១៧៦- កន្ដបខ្ញាញ់ចុក ដេកលក់មិនក្រោក ? . . . ទ្ទើយ

១៧៧- ទទឹងមួយបន្ទប់ ទន្ទឹងតែយប់ លេបមនុស្សទាំងមូល? . . . . . . . . . . . . មុង

១៧៨- អស់ទាំងគេពាក់ចិញ្ចៀនពីមុខ ស្រេសទ្រលុកពាក់ចិញ្ចៀនពីខ្នង? . . . . . . . . . . . . . . . . មុងក្រវិល

១៧៩- លើកជើងរំលងក្បាល? . . . . . . . . . . . . មុង

១៨០- យប់ប៉ោង ថ្ងៃផត? . . . . . . . . . . . មុង

១៨១- យប់ផត ថ្ងៃប៉ោង? . . . . . . . . . . . . ឆត្រ

១៨២- មួយត្របកពីលើ មួយត្របកពីក្រោម ដំម្រែត គ្នាព្រឹម ស្រណុកកាល់ព្រឹក? . . . . . . . ភ្នែក

បណ្ដៅ ដោះស្រាយ

១៨៣ - មមិសពីលើ មមិសពីក្រោម ទន្ទិចគ្នាព្រម
ស្រណុកកាល់ព្រឹក? . . . . . . . . . . . ភ្នែក

១៨៤ - ស្បូវមួយកណ្ដាប គ្របមាត់អណ្ដូង? . . . . . . រោមភ្នែក

១៨៥-ពីតូចទូលដី ធំឡើងមិនចេះស្ដី ស្លៀកពាក់ស្បង់ចីវរ? ទំពាំង

១៨៦ - កំពីងពួយអើយ ពីទុះនៅចង កំពីងពួយចង
ចង់ហើយស្រាយវិញ? . . . . . . . . . ចងគាត

១៨៧ - សេះបួនបួនទឹងតម្ងាំង ទូកបួនប្រែប្រាំង អគ្គី
មានទឹក មច្ឆាហែបហែលអើក អគ្គីមានទឹក
មានស្ដេចមានពស្ត្រ? . . . . . . . . . . ចត្រង្គ

១៨៨- តតាំងចម្បាំងលើតទីព ពលសេហ៍ខ្ជាន់ខ្ជាប់ សង្គ្រាម
ជយា តតាំងប្រណាំងប្ញា ដឹងចាញ់ឈ្នះគ្នា
ហើយច្បាំងម្ដងទៀត? . . . . . . . . . . ចត្រង្គ

១៨៩ - លលូកលលេប លលេងបន្តិច លលេបស៊ីតា
ថាលៗលេងមេណា លលេបសីតា ព្រះរាម
ស្ដេចខ្វល់? . . . . . . . . . . . . . . ចត្រង្គ

១៩០ - តែងតោងប្រហោងតល់បាត មាត់ទំសង្វាត តោះ
លើងគេង? . . . . . . . . . . . . . . បន្ទាស

បញ្ហា ដោះស្រាយ

១៩១- កុកដូចគត្នាត ខំស៊ីសង្កាត រកពោះដាក់គ្មាន? . កណ្ដៀរ

១៩២- នាងអើយនាងម៉ា អស់ប្រាំវស្សា មិនទាន់ផ្កាមួង? ស្លឹកគ្រៃ

១៩៣- កុកដូចកន្ទុង សំយុងដូចកន្ទាត ខំស៊ីសង្កាត រក
ពោះដាក់គ្មាន? . . . . . . . . . . . . . វែក

១៩៤- ដំបូកមួយ មានរន្ធប្រាំពីរ? . . . . . . . . . ក្បាលមនុស្ស

១៩៥- ពីតូចសក់ស្កូវ ដល់ធំតូវម៉ូវ សក់ស្កូវបាត់អស់? ផ្លែថ្កូវ

១៩៦- ស្រីខ្មៅស្រអែម ក្បាលផ្អែម កន្ទុយសាប? . . អំពៅ

១៩៧- ស្រីសដប្បារ មនុស្សគ្រប់ភាសា ប្រាថ្នាស្រស់? ប្រាក់

១៩៨- ស្រីលឿងខ្សៀវខ្ចូ មនុស្សលើផែនដី ខានមេត្រី
គ្រប់គ្នា? . . . . . . . . . . . . . . . . មាស

១៩៩- មេស្អូត កូនកាច? . . . . . . . . . . . . . ស្បូវ

២០០- ស្លឹកដូងសំយាក ស្លឹកចាកសំយុង ពពេលបួន
ផ្ទុង នរណាហ៊ានកាត់? . . . . . . . . អណ្ដាត

២០១- ឈើគោងរលងភ្នំ ត្រដេវរុំចយំ កែវអើយ
ស្រងាត់? . . . . . . . . . . . . . . . . ធ្នូ(ធ្នូធន្ទូ)

២០២- លតាដើមវាន្ធារក្ដាត់ ម្ដេចឡើយមានចិត្ត ចង់ផល់

| បណ្ដៅ | ដោះស្រាយ |
|---|---|
| បព្ចា លាៗលលេងទេណា៎ មុតដៃសីតា ព្រះរាមស្ដេចខ្ញាល់ ? . . . . . . . . . | វល្លិប្រិងលំភ្នំ<br>លំពែងព្រះរាម |
| ២០៣ – កាច់តែកើតជាអ្នក ចាប់ចោលទៅមុខ ពុំទុក ឡើយណា ចាប់បានទាំងជាយក្រែងរ៉ា ចោល កន្ទុំគន្លា ប៉ុនស្រែអំពក ? . . . . . . . | បង់សំណាញ់ |
| ២០៤ – អង្គុយលើមែក រហែកក្ដិត ? . . . . . . . | ផ្លែសំរោង |
| ២០៥ – មួយត្របកបី មួយត្របកបួន មួយត្រកង មួយ ត្រកួន មួយដន្ទាប់មាសក្នុង ? . . . . . | ផ្លែភ្លូ ឬផ្កាឈូក |
| ២០៦ – ខ្លួនប៉ុនកដៃ ក្បាលក្រហមឆៅ រុករុញចូល ទៅ ហៀរទឹកមាត់ទឹកក ? . . . . . . . | ច្រនុះដាំបាយ |
| ២០៧ – ថ្ងៃអើយអ្នកថ្ងៃ ខ្លួនប៉ុនក្ដិតដៃ លេបនគរមួយ បាន លេបទាំងសម្បត្តិ លេបទាំងពិមាន លេប នគរមួយបាន ទើបហៅអ្នកថ្ងៃ ? . . . . | បំពង់ព្រះបត់ |
| ២០៨ – ប៉ុនកដៃអាល័យគួរ ? . . . . . . . . . | កន្ទុយគោ |
| ២០៩ – ពីក្មេងតូចលើ ធំឡើងចេះធ្វើ ឲ្យធំលើជាងក្រោម | ផ្លែស្វាយចន្ទី |

បណ្ដៅ　　　　　　　　　　　　　　　ដោះស្រាយ

២១០- ជើងបួនទល់មេឃ ជើងបួនទល់ដី ក្បាលបី ភ្នែក
ប្រាំមួយ? . . . . . . . . . . . . . . . . . មនុស្សសែង ជ្រូក

២១១- ក្ដិតទល់ក្ដិត ក្បាលទល់ក្បាល ស្នូកនៅកណ្ដាល
បែកញើសជោក? . . . . . . . . . . . . . . សង្រែក

២១២- មានរូបមើលមិនឃើញ តែចាប់បាន? . . . . . ចាប់ខ្យល់

២១៣- ដើមម្រេចដុះលើដើមឬស្សី ស្លឹកបី ផ្លែមួយ? . . ស្លាធំ

២១៤- ខ្ទឹតៗ ស្ទាបៗ រលាបៗ ខ្ទឹតទៀត? . . . . . . សំលៀងកាំបិត

២១៥- អាសោមហៀរ អាសោមហៃ ចាប់បានដៃអាសោម
ហៀរ ស៊ីសាច់ខ្ជាក់គ្រាប់ កញ្ច្រោប កន្ទ្រេង
ក្រង? . . . . . . . . . . . . . . . . . . ផ្តោះពោះ កប្បាស

២១៦- ស្រីសត្រសោក ដុះមមិសត្រពោក អន្ទុយនៅពង
ផ្ការ? . . . . . . . . . . . . . . . . . . មើមខ្ទឹម

២១៧- អាបួននាក់សែងកូប អាក្រឡិតដើរមុខ? . . . . អណ្ដើក

ជម្មបនកាសិត

# លោកគ្រូចៅអធិការ ( ឯក-ញឹម )

វត្តធម្មិស្សរោកម ឃុំ-ស្រុកសូទ្រនិគម ខេត្តសៀមរាប

រៀបរៀង

ពួកគាថា ប្រែជាបទបញ្ជាក់ក្នុងសៀវភៅនេះ ខ្ញុំព្រះករុណាអាត្មាភាព (ឯក-ញឹម) នាម ធម្មិស្សរោ ចៅអធិការវត្តធម្មិស្សរោកម ឃុំសូទ្រនិគម ស្រុកសូទ្រនិគម ខេត្តសៀមរាប ។

បានស្រង់យកគាថាទានានាក្នុងគម្ពីរផ្សេងៗ មានគម្ពីរធម្មបទ ខុទ្ទក-និកាយជាដើម មកប្រែរៀបរៀងធ្វើជាពាក្យប្រាំបី ឲ្យត្រូវតាមរបៀបបាលីក្នុងគាថាទាំងឡាយនោះៗ ដើម្បីជាប្រយោជន៍ឲ្យស្រួលដល់លោកអ្នកសិក្សាទាំងឡាយផង ដើម្បីជាប្រយោជន៍ដល់ការសូត្រក្នុងទីប្រជុំបុណ្យទាំងឡាយ មានបុណ្យពុទ្ធវិសាខបូជាជាដើមផង ដើម្បីនឹងបានបោះពុម្ពផ្សាយចែកជាធម្មទាន ក្នុងឱកាសបុណ្យបញ្ចុះសីមា វត្តធម្មិស្ស-រោកម នៅថ្ងៃអាទិត្យ ១១កើតខែមិគសិរ ឆ្នាំរកាឆស័ក ព.ស.២៤៨៧ផង ។

លុះរៀបរៀងរួចហើយ បានបង្ហាញដល់ពុទ្ធបរិសទ្យទាំងឡាយ មានព្រះបុរីគោគា តាន់-នេងស៊ុយជាដើម ពុទ្ធបរិសទ្យទាំងឡាយនោះ លុះមើលឃើញរបៀបធម៌នេះសព្វគ្រប់ហើយ ក៏កើតចិត្តជ្រះថ្លាបានចំណាយហិរញ្ញវត្ថុគ្រប់ៗគ្នា តាមលំដាប់ទិសសីមាទាំង៩ទិស ។ ហើយបាននិមន្តខ្ញុំព្រះករុណាអាត្មាភាព ឲ្យចាត់ការបោះពុម្ពផ្សាយ

ចែកជាធម្មទាន ក្នុងឱកាសបុណ្យសីមាវត្តនោះ នៅថ្ងៃដូចថាមកខាងលើស្រាប់ តែសម័យនេះស្រុកក្រក្រជាសពន់ពេក ហើយខ្ញុំព្រះករុណាអាត្មាភាពផ្ញើមកជូនពុទ្ធសាសនបណ្ឌិត្យឲ្យលោកចាត់ការបោះពុម្ពឡើងក្នុងទស្សនាវដ្តីកម្ពុជសុរិយា ឯរបៀបរៀបរៀងគាថាទាំងឡាយនោះដូច្នេះ :

១ — មង្គលសូត្រ ពួកធម៌សំដែងពីសេចក្តីចំរើនមាន ១០ គាថា

២ — បរាភវសូត្រ ពួកធម៌សំដែងពីសេចក្តីវិនាសមាន ១២ គាថា

៣ — យុគគាថា ពួកគាថាសំដែងអំពីធម៌ជាគូៗនឹងគ្នាមាន ១៦ គាថា

៤ — បកិណ្ណកគាថា ពួកគាថាសំដែងពីធម៌ពាយរងមាន ៤៨ គាថា

រួបរួមគាថាទាំងអស់ត្រូវ ៨៦ គាថា ។

សូមសេចក្តីសុខ សេចក្តីចំរើនកើតមានដល់ព្រះពុទ្ធសាសនា និងលោកអ្នកសិក្សាទាំងឡាយផងតទៅ អស់កាលជាអង្វែង ។

## មង្គលសូត្រ

បទ បថ្យាវត្ត

ពហូ ទេវា មនុស្សា ច មង្គលានិ អចិន្តយុំ
អាកង្ខមានា សោត្ថានំ ព្រូហិ មង្គលមុត្តមំ ។

ទេព្តានិងមនុស្សទាំងឡាយមិនយល់ គិតរកមង្គលអស់កាលអង្វែង
ប្រាថ្នាចង់ស្តាប់មង្គលនេះឯង សូមព្រះសំដែងមង្គលឧត្តម ។

ពុទ្ធដីកា ឆ្លើយតបនឹងទេវតា

១– អសេវនា ច ពាលានំ    បណ្ឌិតានញ្ច សេវនា
បូជា ច បូជនីយានំ    ឯតម្មង្គលមុត្តមំ ។
កិរិយាមិនសេពនឹងពាលទាំងឡាយ    សេពនឹងប្រាជ្ញប្រាយសព្វកាលវេលា
បូជាបុគ្គលដែលគួរបូជា    ទាំង ៣ ប្រការមង្គលឧត្តម ។

២– បដិរូបទេសវាសោ ច    បុព្វេ ច កតបុញ្ញតា
អត្តសម្មាបណិធិ ច    ឯតម្មង្គលមុត្តមំ ។
កិរិយានៅក្នុងប្រទេសគួរសម    នឹងធ្វើបុណ្យធំពីមុនច្រើនក្រៃ
កិរិយាដម្កល់ខ្លួនទុកប្រពៃ    អំពើទាំង ៣ មង្គលឧត្តម ។

ពាហុសច្ចញ្ច សិប្បញ្ច    វិនយោ ច សុសិក្ខិតោ
សុភាសិតា ច យា វាចា    ឯតម្មង្គលមុត្តមំ ។
បុគ្គលបានស្ដាប់បានរៀនចេះច្រើន    សិល្បសាស្ត្រចំរើនឆ្លៀវឈ្លាសកងវៃ
វិន័យសិក្ខាវាចាប្រពៃ    ទាំង៤នេះនៃមង្គលឧត្តម ។

៤ – មាតាបិតុឧបដ្ឋានំ    បុត្តទារស្ស សង្គហោ
អនាកុលា ច កម្មន្តា    ឯតម្មង្គលមុត្តមំ ។
កិរិយាបំរើមាតាបិតា    សង្គ្រោះភរិយានិងបុត្រអាត្មា
មិនបានផ្សេងផ្សំណាយឡូកការងារ    ទាំង ៤ នេះជាមង្គលឧត្តម ។

៥ – ទានញ្ច ធម្មចរិយា ច    ញាតកានញ្ច សង្គហោ
អនវជ្ជានិ កម្មានិ    ឯតម្មង្គលមុត្តមំ ។
ការបរិច្ចាគទាននឹងប្រព្រឹត្តធម៌    នឹងសង្គ្រោះល្អដល់ញាតិអាត្មា
នឹងការទាំងឡាយមិនមានទោសា    ទាំង ៤ នេះជាមង្គលឧត្តម ។

៦ - អារតី វិរតី បាបា មជ្ជបានា ច សញ្ញមោ

អប្បមាទោ ច ធម្មេសុ ឯតម្មង្គលមុត្តមំ ។

ការមិនត្រេកអរនឹងវៀរចាកបាប សង្រួមអត្តភាពៈវៀរទឹកស្រវឹង

មិនមានប្រមាទស្មារតីរឹងប៉ឹង ទាំង៣នេះហ្នឹងមង្គលឧត្តម ។

៧ — គារវោ ច និវាតោ ច សន្តុដ្ឋី ច កតញ្ញុតា

កាលេន ធម្មស្សវនំ ឯតម្មង្គលមុត្តមំ ។

សេចក្ដីគោរពនឹងកំឯងភគោស សេចក្ដីសន្ដោសដឹងគុណនានា

និងការស្ដាប់ធម៌តាមកាលវេលា ទាំង ៥ នេះជាមង្គលឧត្តម ។

៨ — ខន្តី ច សោវចស្សតា សមណានញ្ច ទស្សនំ

កាលេន ធម្មសាកច្ឆា ឯតម្មង្គលមុត្តមំ ។

សេចក្ដីអត់ធន់នឹងប្រដៅស្រួល និងការទទួលជួបពួកសមណា

ការសាកសួរធម៌តាមកាលវេលា ទាំង ៤ នេះជាមង្គលឧត្តម ។

៩ - តបោ ច ព្រហ្មចរិយញ្ច អរិយសច្ចាន ទស្សនំ

និព្វានសច្ឆិកិរិយា ច ឯតម្មង្គលមុត្តមំ ។

ព្យាយាមដុតបាបនឹងប្រព្រឹត្តធម៌ និងបានឃើញធម៌អរិយសច្ចា

ធ្វើព្រះនិព្វានច្បាស់ក្នុងអាត្មា ទាំង ៤ នេះជាមង្គលឧត្តម ។

១០ — ផុដ្ឋស្ស លោកធម្មេហិ ចិត្តំ យស្ស ន កម្បតិ

អសោកំ វិរជំ ខេមំ ឯតម្មង្គលមុត្តមំ ។

ចិត្តនៃបុគ្គលកាលលោកធម៌ ប៉ះមិនញាប់ញ័រមិនមានសោកា

ប្រាសចាកធុះម្រែកក្សេមក្សាន្តចិត្តា ទាំង ៤ នេះជាមង្គលឧត្តម ។

៦ — ឯតាទិសានិ កត្វាន សព្វត្ថមបរាជិតា
សព្វត្ថ សោត្ថឹ គច្ឆន្តិ តន្តេសំ មង្គលមុត្តមំ ។

ទេវតានិងមនុស្សធ្វើដូច្នេះហើយ    មិនចាលចាញ់ឡើយក្នុងទីនានា
បានដល់សួស្តីសិរីសុខា    ទាំងមនុស្សទេវតាផលឧត្តម ។

( មង្គលសុត្តំ និដ្ឋិតំ ។ )

## បរាភវសុត្ត

## បទ បជ្ជាវត

បរាភវន្តំ បុរិសំ មយំ បុច្ឆាម គោតមំ
ភវន្តំ បុដ្ឋុមាគម្ម កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយមកសូមទូលសួរ    នូវហេតុជាគ្រឿងវិនាស
បុរសបុគ្គលដែលដល់ឱកាស    ហើយនឹងវិនាសសាបសូន្យបាត់គុណ
នឹងព្រះគោតមព្រះអង្គមានបុណ្យ    បេត្តានិមន្តសំដែងឲ្យទាន
ធម្មជាតដូចម្តេចដែលជាប្រធាន    នាំសត្វឲ្យមានសេចក្តីវិនាស ។

ព្រះពុទ្ធដីកា ឆ្លើយតបនឹងទេវតាថា

១— សុវិជានោ ភវំ ហោតិ ទុវិជានោ បរាភវោ
ធម្មកាមោ ភវំ ហោតិ ធម្មទេស្សី បរាភវោ ។

អ្នកចេះដឹងល្អតែងបានចំរើន    ទ្រព្យធនបុណ្យកើនកើតពីវិជ្ជា
ចំណេះអាក្រក់ឥតសិល្បសាស្ត្រ    អ្នកនោះឈ្មោះជាវិនាសដោយពិត
អ្នកប្រាថ្នាធម៌ដោយល្អក្នុងចិត្ត    ហើយទំប្រព្រឹត្តនឹងបានចំរើន
អ្នកទ្រុស្តក្នុងធម៌ឬស្អប់ធម៌ច្រើន    អ្នកនោះចំរើនវិនាសទៅមុខ ។

២ - អសន្តស្ស បិយា ហោន្តិ សន្តេ ន កុរុតេ បិយំ
អសតំ ធម្មំ រោចេតិ តំ បរាភវតោ មុខំ ។

អ្នកដែលស្រឡាញ់ពេញចិត្តស្នេហា  តែនឹងមនុស្សណាអសប្បុរស
តែងមិនស្រឡាញ់ពេញចិត្តទាំងអស់  នឹងអ្នកសប្បុរសមកធ្វើជាមិត្រ
សេចក្តីស្រឡាញ់ពេញចិត្តជំនិត  ហើយទៅគប់មិត្រអសប្បុរស
ជាប់ចិត្តក្នុងធម៌ឬមួយរបស់  ហេតុនោះទាំងអស់នាំឲ្យវិនាស ។

៣ - និទ្ទាសីលី សភាសីលី អនុដ្ឋាតា ច យោ នរោ
អលសោ កោធបញ្ញាណោ តំ បរាភវតោ មុខំ ។

អ្នកដេកច្រើនមួយនិយាយច្រើនមួយ  នឹងអ្នកឥតព្យាយាមគិតប្រឹងប្រែង
ខឹងខ្ជិលច្រអូសមិនមានខ្នះខ្នែង  ខឹងច្រើនសំដែងឲ្យគេឃើញបាន ។
ហេតុធម៌ទាំងនោះមិនជាកល្យាណ  នាំឲ្យខកខានខាតខូចប្រយោជន៍
មានជាប្រធានតិចច្រើនដោយហោច  នាំបង់ប្រយោជន៍ហើយឲ្យវិនាស ។

៤ - យោ មាតរំ វា បិតរំ វា ជិណ្ណកំ គតយោព្វនំ
បហុសន្តោ ន ភរតិ តំ បរាភវតោ មុខំ ។

នរជនណាមានទ្រព្យធនធាន  ហើយខ្លួនមិនមានចិញ្ចឹមរក្សា
មាតាបិតាដែលចាស់ជរា  ហេតុនោះទៅជានាំឲ្យវិនាស ។

៥ - យោ ព្រាហ្មណំ វា សមណំ វា អញ្ញំ វាបិ វនិព្វកំ
មុសាវាទេន វញ្ចេតិ តំ បរាភវតោ មុខំ ។

ជនបញ្ឆោតព្រាហ្មណ៍ឬពួកសមណៈ  ពួកស្មូមឬអ្នកដទៃ
ដោយមុសាវាទឃ្លាតពាក្យប្រពៃ  នោះប្រាកដនៃសេចក្តីវិនាស ។

៦- បហុតវិត្តោ បុរិសោ សហិរញ្ញោ សភោជនោ
ឯកោ ភុញ្ជតិ សាទូនិ(១) តំ បរាភវតោ មុខំ ។
បុរសអ្នកមានទ្រព្យធនធានច្រើន មាសប្រាក់ចំណីនឹងគ្រឿងអាហារ
លបលាក់របស់ឆ្ងាញ់ពិសា តែម្នាក់ឯងជាប្រធានវិនាស ។

៧- ជាតិថទ្ធោ ធនថទ្ធោ គោត្តថទ្ធោ ច យោ នរោ
សញ្ញាតឹ អតិមញ្ញេតិ តំ បរាភវតោ មុខំ ។
អ្នកដែលប្រកាន់ជាតិទ្រព្យត្រកូល ហើយមិនប្រមូលគាប់ញាតិសន្តាន
មើលងាយញាតិខ្លួនដោយអាងខ្លួនមាន នោះជាប្រធានសេចក្តីវិនាស ។

៨- ឥត្ថិធុត្តោ សុរាធុត្តោ អក្ខធុត្តោ ច យោ នរោ
លទ្ធំ លទ្ធំ វិនាសេតិ តំ បរាភវតោ មុខំ ។
ជនអ្នកប្រព្រឹត្តល្បែង ៣ ប្រការ ល្បែងស្រីល្បែងស្រាល្បែងភ្នាល់ទាំងឡាយ
ធ្វើទ្រព្យខ្លួនមានឲ្យអន្តរាយ ការល្បែងទាំងឡាយនោះនាំវិនាស ។

៩- សេហិ ទារេហិ អសន្តុដ្ឋោ វេសិយាសុ បទុស្សតិ
ទុស្សតិ បរទារេសុ តំ បរាភវតោ មុខំ ។
បុរសមិនត្រេកនឹងស្រីភរិយា ហើយទៅត្រូវការនឹងស្រីពេស្យា
ទ្រុស្តនឹងប្រពន្ធកូនជនដទៃ ហេតុនោះទៅជានាំឲ្យវិនាស ។

១០. អតីតយោព្វនោ បោសោ អានេតិ តិម្ពរុត្ថនឹ
តស្សា ឥស្សា ន សុបតិ តំ បរាភវតោ មុខំ ។
បុរសមានផែលចាស់ហួសពេក ហើយនៅនិទ្រាដោយក្តីតណ្ហា
នាំយកស្រីក្មេងមកធ្វើភរិយា ហេតុនោះទៅជានាំឲ្យវិនាស ។

---
១ ឆ. សាទូនិ ក៏មាន ។

១១- ឥត្ថឹ សោណ្ឌឹ វិកិរណឹ បុរិសំ វាបិ តាទិសំ
ឥស្សរិយស្មឹ ឋបេតិ តំ បរាភវតោ មុខំ ។

បុរសតាំងស្រីអ្នកលេងខ្ជះខ្ជាយ ឬស្រីទាំងឡាយតាំងបុរសនោះ
ដែលជាអ្នកលេងខ្ជះខ្ជាយជូរប្រោះ អំពើទាំងនោះនាំឲ្យវិនាស ។

១២- អប្បភោគោ មហាតណ្ហោ ខត្តិយេ ជាយតេ កុលេ
សោ ច រជ្ជំ បត្ថយតិ តំ បរាភវតោ មុខំ ។

ជនណាកើតក្នុងត្រកូលជាក្សត្រ អ្នកខ្សត់សម្បត្តិហើយប្រាថ្នាធំ
ចង់បានជាស្តេចសោយរាជ្យស្តុកស្តម្ភ ហេតុនោះនឹងនាំឲ្យដល់វិនាស ។

១៣- ឯតេ បរាភវេ លោកេ បណ្ឌិតោ សមវេក្ខិយ
អរិយោ ទស្សនសម្បន្នោ ស លោកំ ភជតេ សិវំ ។

ជនជាបណ្ឌិតគំនិតប្រសើរ បានឃើញដំណើរនៃហេតុវិនាស
ដល់សត្វក្នុងលោកសង្វាស គេចពីវិនាសគប់រកចំរើន ។

( បរាភវសុត្តំ និដ្ឋិតំ ។ )

## យុគគាថា

### បឋម បជ្ជាវគ

១- មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា
មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា
តតោ នំ ទុក្ខមន្វេតិ ចក្កំវ វហតោ បទំ ។

ធម៌ទាំងឡាយមានចិត្តជាប្រធាន ប្រសើរក្នុងប្រាណស្រេចបានដោយចិត្ត
បើបុគ្គលមានមនោទុច្ចរិត ពោលឬប្រព្រឹត្តធ្វើអំពើបាប ។

ទុក្ខតែងទៅតាមអ្នកនោះដរាប ព្រោះអំពើបាបនៃបុគ្គលនោះ
ដូចកង់រទេះវិលតាមជំពោះ ស្នាមជើងគោស្មោះក្នុងទីនោះឯង ៕

២- មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា
មនសា ចេ បសន្នេន ភាសតិ វា ករោតិ វា
តតោ នំ សុខមន្វេតិ ឆាយាវ អនបាយិនី ៕

ធម៌ទាំងឡាយមានចិត្តជាប្រធាន ប្រសើរក្នុងប្រាណស្រេចដោយចិត្ត
បើបុគ្គលមាគមនោសុចរិត ផ្សះថ្លាប្រព្រឹត្តពោលឬធ្វើក្តី ៕
សុខតែងទៅតាមអ្នកនោះប្រក្រតី ព្រោះអំពើនៃបុណ្យបុគ្គលនោះ
ដូចជាស្រមោលទៅតាមជំពោះ នៃរូបកាយនោះប្រាកដជាក់ស្តែង ៕

៣- អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ
យេ ច តំ ឧបនយ្ហន្តិ វេរំ តេសំ ន សម្មតិ ៕

ពួកជនឯណាចងក្រោធទុកថា គេជេរអាត្មាគេវាយគេផ្ចាញ់
គេលួចយកទ្រព្យរបស់ផងអញ ពៀរជននោះឯងមិនរម្ងាប់ឡើយ ៕

៤- អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ
យេ ច តំ នុបនយ្ហន្តិ វេរំ តេសូបសម្មតិ ៕

ពួកជនឯណាមិនចងពៀរថា គេជេរអាត្មាគេវាយគេផ្ចាញ់
គេលួចយកទ្រព្យរបស់ផងអញ ពៀរជននោះឯងនឹងរម្ងាប់បាន ៕

៥- សុភានុបស្សឹ វិហរន្តំ ឥន្ទ្រិយេសុ អសំវុតំ
ភោជនម្ហិ អមត្តញ្ញុំ កុសីតំ ហីនវីរិយំ
តំ វេ បសហតិ មារោ វាតោ រុក្ខំវ ទុព្វលំ ៕

មារតែងតែគ្របសង្កត់បុគ្គល ឃើញរូបហើយយល់អារម្មណ៍ថាល្អ
មិនសង្រួមហើយក្នុងឥន្ទ្រិយធម៌ មិនមានដឹងប្រមាណក្នុងភោជន
ខ្ជិលច្រអូសហើយមានព្យាយាមទន់ បានដូចព្យុះធ្ងន់កាប់ឈើទ្រេតស្រាប់ ។

៦- អសុភានុបស្សឹ វិហរន្តំ ឥន្ទ្រិយេសុ សុសំវុតំ
ភោជនម្ហិ ច មត្តញ្ញុំ សទ្ធំ អារទ្ធវីរិយំ
តំ វេ នប្បសហតី មារោ វាតោ សេលំវ បព្វតំ ។

មារមិនអាចគ្របសង្កត់បុគ្គល ឃើញអារម្មណ៍យល់ថាមិនមានល្អ
សង្រួមល្អហើយក្នុងឥន្ទ្រិយធម៌ ជាអ្នកដឹងប្រមាណក្នុងភោជន
មានចិត្តជឿជាក់ព្យាយាមក៏ធ្ងន់ ដូចខ្យល់ព្យុះទន់កាប់ភ្នំមិនបាន ។

៧- យថា អគារំ ទុច្ឆន្នំ វុដ្ឋិ សមតិវិជ្ឈតិ
ឯវំ អភាវិតំ ចិត្តំ រាគោ សមតិវិជ្ឈតិ ។

ភ្លៀងតែងលេចបានផ្ទះប្រក់មិនល្អ ដូចរាគៈធម៌លេចស្រោចសន្តាន
បុគ្គលដែលមិនចំរើនកម្មដ្ឋាន រាគៈតែងរុកបានធ្លុះធ្លាយដល់ចិត្ត ។

៨- យថា អគារំ សុច្ឆន្នំ វុដ្ឋិ ន សមតិវិជ្ឈតិ
ឯវំ សុភាវិតំ ចិត្តំ រាគោ ន សមតិវិជ្ឈតិ ។

ភ្លៀងលេចមិនបានផ្ទះគេប្រក់ល្អ ដូចរាគៈធម៌មិនស្រោចសន្តាន
បុគ្គលដែលបានចំរើនកម្មដ្ឋាន រាគៈរុកមិនបានធ្លុះធ្លាយដល់ចិត្ត ។

៩- អនយំ នេតិ ទុម្មេធោ អធុរាយំ និយុញ្ជតិ
ទុន្នយោ សេយ្យសោ ហោតិ សម្មា វុត្តោ ច កុប្បតិ
វិនយំ សោ ន ជានាតិ សាធុ តស្ស អទស្សនំ ។

មនុស្សគិតប្រាជ្ញាតែងតែណែនាំ　　នូវហេតុមិនសមដោយគិតកាន់កាំង
នាំឲ្យប្រកបភាគខ្វះកំលាំង　　ធុរៈដែលតាំងមិនត្រូវតាមធម៌
ជាមនុស្សគឺគេប្រដៅដោយក្រ　　និយាយពាក្យល្អក៏មិនប្រែឡោតទឹង
ច្បាប់ធម៌វិន័យក៏គ្មានពេះដឹង　　ជននោះយើងនឹងឈប់ឃើញប្រពៃ ។

១០– នយំ នយតិ មេធាវី　　អធុរាយំ ន យុញ្ជតិ
សុនយោ សេយ្យសោ ហោតិ　　សម្មា វុត្តោ ន កុប្បតិ
វិនយំ សោ បជានាតិ　　សាធុ តេន សមាគមោ ។

មនុស្សមានប្រាជ្ញាតែងតែដឹកនាំ　　នូវហេតុដែលសមមិនបានខុសទោរ
មិននាំប្រកបដោយក្តីពាលោ　　អំពើមោហោមិនប្រកបកាយ
ជាមនុស្សគឺគេប្រដៅដោយងាយ　　ពាក្យល្អនិយាយមិនប្រែឡោតវិង
ច្បាប់ធម៌វិន័យក៏បានចេះដឹង　　ជននោះយើងនឹងនៅរួមប្រពៃ ។

១១– បាបញ្ចេ បុរិសោ កយិរា　　ន តំ កយិរា បុនប្បុនំ
ន តម្ហិ ឆន្ទំ កយិរាថ　　ទុក្ខោ បាបស្ស ឧច្ចយោ ។

បុរសប្រុសស្រីបើបានធ្វើ　　នូវកម្មអំពើអាក្រក់នោះហើយ
កុំធ្វើបាបនោះថែមរឿយៗ ឡើយ　　កុំពេញចិត្តហើយក្នុងបាបទាំងនោ
ការសន្សំបាបនាំមកចំពោះ　　នៅទោសទុក្ខនោះដល់អង្គអាត្មា ។

១២– បុញ្ញញ្ចេ បុរិសោ កយិរា　　កយិរាថេនំ បុនប្បុនំ
តម្ហិ ឆន្ទំ កយិរាថ　　សុខោ បុញ្ញស្ស ឧច្ចយោ ។

បុរសប្រុសស្រីបើធ្លាប់បានធ្វើ　　នូវកម្មអំពើជាបុណ្យនោះហើយ
ត្រូវធ្វើបុណ្យនោះថែមឡើងរឿយៗ　　ត្រូវពេញចិត្ត ហើយក្នុងបុណ្យនោះៗ
ការសន្សំបុណ្យនាំមកចំពោះ　　នូវក្តីសុខនោះដល់អង្គអាត្មា ។

១៣– បាបោ បិ បស្សតិ ភទ្រំ យាវ បាបំ ន បច្ចតិ
យទា ច បច្ចតិ បាបំ អថ បាបានិ បស្សតិ ។

អ្នកធ្វើអាក្រក់ត្រឡប់បានសុខ បាបដែលធ្វើទុកមិនទាន់ឲ្យផល
លុះបាបឲ្យផលកាលណាទើបស្គាល់ បាបបុគ្គលយល់បាបកាលនោះ ។

១៤– ភទ្រោបិ បស្សតិ បាបំ យាវ ភទ្រំ ន បច្ចតិ
យទា ច បច្ចតិ ភទ្រំ អថ ភទ្រានិ បស្សតិ ។

អ្នកធ្វើការល្អតែមិនបានសុខ បុណ្យដែលធ្វើទុកមិនទាន់ឲ្យផល
លុះបុណ្យឲ្យផលកាលណាទើបស្គាល់ ភទ្របុគ្គលយល់បុណ្យកាលនោះ ។

១៥– មាវមញ្ញេថ បាបស្ស ន មត្តំ អាគមិស្សតិ
ឧទពិន្ទុនិបាតេន ឧទកុម្ភោបិ បូរតិ ។
បូរតិ ពាលោ បាបស្ស ថោកំថោកម្បិ អាចិនំ ។

បុគ្គលមិនគួរមើលងាយបាបឡើយ ថាតិចតួចហើយមិនងាយឲ្យផល
ដូចពាងបើកមាត់រមែងតែងដល់ ពេញដោយមិនសល់នឹងដំណក់ទឹក ។
ពាលសន្សំបាបតិច ៗ ញាក ៗ ញយ ៗ សន្ធឹកពេញដោយបាបបាន ។

១៦– មាវមញ្ញេថ បុញ្ញស្ស ន មត្តំ អាគមិស្សតិ
ឧទពិន្ទុនិបាតេន ឧទកុម្ភោបិ បូរតិ
បូរតិ ធីរោ បុញ្ញស្ស ថោកំថោកម្បិ អាចិនំ ។

បុគ្គលមិនគួរមើលងាយបុណ្យឡើយ ថាតិចតួចហើយមិនងាយឲ្យផល
ដូចពាងបើកមាត់រមែងតែដល់ ពេញដោយមិនសល់នឹងដំណក់ទឹក
ប្រាជ្ញសន្សំបុណ្យរឿយ ៗ ញឹក ៗ ញយ ៗ តន្ទឹកពេញដោយបុណ្យបាន ។

(មានត)

ឯកសារ តនៃមិលិន្ទបញ្ហា

ហ្វូងទំពន្ធមន្ត្រី ញ៉ុក - ថែម ប្រែនិងរៀបរៀង

(តមក)

១ — ជាអ្នកត្រេកអរយ៉ាងក្រៃលែង ក្នុងសេចក្ដីសុខដែលកើតអំពីសេចក្ដីស្ងប់ស្ងាត់ដ៏ក្រៃលែងប៉ុណ្ណោះ ។

២ — ផ្គងផ្គងចិត្តឲ្យរីករាយ មិនខ្ជិលច្រអូសស្ងប់ស្ងាប់នៅក្នុងកុសលធម៌ទាំងឡាយ កើតសេចក្ដីរីករាយ ៖ សម្រាប់ព្យាយាមបំពេញកុសលធម៌ទាំងឡាយ ។

៣ — មិនដែលកើតចិត្តនឿយណាយនឹងផ្ទះស្ងាត់ទំនេរនោះឡើយ ។

## អង្គ ៣ របស់សត្វទ្រយៈ

១ — នៅក្នុងព្រៃតែវេលាថ្ងៃ លុះដល់យប់តែងចេញទៅនៅក្នុងទីវាល ។

២ — គេចចៀសលំពែង ឬកូនសរដែលធ្លាក់មកត្រូវលើខ្លួនផុតរបូតទៅបាន ហើយមិនដែលបង្អោនកាយទៅរកកូនសរនោះឡើយ ។

៣ — កាលបានមកប្រទះនឹងមនុស្សហើយ ក៏លាក់ខ្លួនពួនសំងំនៅក្នុងទីណាមួយ មិនឲ្យមនុស្សមើលឃើញខ្លួនឡើយ ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៣ ប្រការគឺ:

១_វេលាថ្ងៃនៅតែក្នុងព្រៃ ដល់យប់ចេញមកនៅកណ្ដាលវាល ។

២–កាលកិលេសកើតឡើង ក៏ចៀសគេចរត់ចេញមិនបង្អោនចិត្ត ទៅប្រឡូកប្រឡល់នឹងកិលេសទាំងនោះឡើយ ។

៣–ឃើញផលដទៃបន្តដំណោះរាំទ ឬស្ត្រីសីលខ្ពល់ប្រអូសក៏ គេចចៀសពាំងឲ្យឆ្ងាយទៅ មិនឲ្យផលទាំងនោះឃើញ ទាំងខ្លួនឯងសោត ក៏មិនចង់ជួបប្រទះនឹងផលទាំងនោះឡើយ ។

## អង្គ ៣ របស់សត្វចាក្រពាកៈ

១— មិនបោះបង់ចោលគូស្រករបស់ខ្លួនដរាបដល់អស់ជីវិត ។

២—មានស្មៅសារាយទឹងចកពងទឹកជាអាហារ ក៏ពេញចិត្តត្រេកអរ ដោយអាហារនោះ ទុកជាត្រេកអរដោយអាហារបែបនេះ ក៏មិនរៀររោយខ្យល់បក់ឡាំង នឹងសំបុរកាយទៅឡើយ ។

៣—មិនបៀតបៀនជីវិតសត្វដទៃឡើយ ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៣ ប្រការគឺ:

១ –មិនលះបង់យោនិសោមនសិការៈ ដរាបដល់អស់ជីវិត ។

២—ជាអ្នកសន្ដោស ទុកជាសន្ដោសដូច្នេះ ក៏មិនសាបសូន្យចាក កុសលធម៌ទាំងពួងឡើយ គ្រឡប់ជាចរិបូណ៌ដោយសីល សមាធិ បញ្ញា វិមុត្តិញាណទស្សនៈ ។

៣– មានសេចក្តីខ្មាសអៀនមិនហ៊ានកន្លងល្មើសអំពើដែលគួរខ្មាស មិនបៀតបៀនជីវិតសត្វទៅ មានចិត្តប្រកបដោយមេត្តាករុណាកន្ទក់សត្វទាំងពួង ។

## អង្គ ៣ របស់ពស់ៈ

១ – លូនកាវទៅដោយដើមទ្រូង ។

២ – លូនទៅប្រទះនឹងដើមស្មៅ ក៏គេចបេញឲ្យផុតពីដើមស្មៅ ។

៣ – ប្រទះនឹងមនុស្ស ក៏កើតសេចក្តីក្តៅក្រហាយចិត្តគិតភ័យគិតតែគេចចៀសឲ្យផុតទៅ ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៣ ប្រការគឺៈ

១ – ត្រាច់ទៅដោយប្រាជ្ញា វៀរចាករបស់ដែលមិនមែនជាលក្ខណៈចំរើនតែរបស់ដែលជាលក្ខណៈ គឺព្រះត្រៃលក្ខណ៍ ។

២ – វៀរចាកទុច្ចរិត ។

៣ – ចួនជាកើតសេចក្តីត្រិះរិះទៅក្នុងវិតក្កខុសហើយ ក៏កើតសេចក្តីមិនពេញចិត្តខ្លួនឯង មានសេចក្តីក្តៅក្រហាយ ស្តាយក្រោយហើយផ្លាស់ចិត្តគំនិត មកត្រិះរិះក្នុងកុសលវិតក្កវិញភ្លាម ជាអ្នកមិនប្រមាទ ព្រោះយប់ថ្ងៃកន្លងទៅហើយ មិនត្រឡប់មកវិញឡើយ ។

## អង្គ ៣ របស់ដើមឈើ ៈ

១— ទ្រទ្រង់នូវផ្លែនិងផ្កា ។

២— ឲ្យពួកមនុស្សចូលអាស្រ័យម្លប់បាន ។

៣— មានម្លប់ផ្សាយបញ្ចេញទៅជានិច្ច មនុស្សចូលទៅអាស្រ័យបានគ្រប់គ្នាមិនរើសមុខ ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៣ ប្រការគឺ ៈ

១— ទ្រទ្រង់នូវផលគឺវិមុត្តិ និងផ្កាគឺសាមញ្ញផល ។

២— កាលបើមានភ្ញៀវចូលមករកខ្លួនក៏ចាត់ ដោយអាមិសប្បដិសណ្ឋារៈនិងធម្មប្បដិសណ្ឋារៈ ។

៣— មានសេចក្ដីស្មើភាគ ប្រាសចាកអគតិ ៤ ប្រការ ចំរើនមេត្តាករុណាដល់សព្វសត្វទៅស្មើភាគគ្នា ។

## អង្គ ៣ របស់ឆត្រ ៈ

១— សម្រាប់បាំងនៅលើក្បាល ។

២— ការពារក្បាលឲ្យត្រជាក់ស្រួល ។

៣— បង្ការថ្ងៃនិងភ្លៀងបាន ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៣ ប្រការគឺ ៈ

៣ - ជាអ្នកត្រាច់ទៅលើកិលេសទាំងឡាយ ។

៤ - ទំនុកបំរុងយោនិសោមនសិការឲ្យកាន់តែចំរើនឡើង ។

៣ - កំចាត់ថ្ងៃភ្លើង ៣ កង ភ្លើងគឺរាគៈ ភ្លើងគឺទោសៈ ភ្លើងគឺមោហៈ និងភ្លើងគឺកិលេសចេញបាន ។

## អង្គ ៣ របស់ស្រែ៖

១ - បរិបូណ៌ដោយប្រឡាយទឹក សម្រាប់អ្នកស្រែការស្រើយ បង្ហូរចូលទៅក្នុងស្រែក្របស្រែសន្ធឹង ។

២ - បរិបូណ៌ដោយភ្លឺ សម្រាប់អ្នកស្រែទប់ទឹកទុកទំនុកបម្រុងដើមស្រូវឲ្យមានផ្លែផ្កា ។

៣ - បរិបូណ៌ដោយពូជស្រូវ ញាំងម្ចាស់ស្រែឲ្យសប្បាយចិត្ត ព្រោះបើគេព្រោះសាបពូជតែបន្តិចបន្តួចក៏មានផលច្រើន បើព្រោះសាបពូជច្រើន ក៏កាន់តែមានផលច្រើនឡើងទៅទៀត ។

ប្រៀបដូចអ្នកប្រតិបត្តិ ប្រកបដោយអង្គសម្បត្តិ ៣ ប្រការគឺ៖

១ - បរិបូណ៌ដោយសេចក្ដីសុចរិត និងវត្តប្រតិបត្តិដូចជាប្រឡាយទឹក ។

២ - រក្សាសមណធម៌ដោយសីលដូចជាភ្លឺស្រែ ដើម្បីឲ្យបានសម្រេចសាមញ្ញផលទាំង ៤ ។

៣ — បរិបូណ៌ដោយព្យាយាម ៖ បង្កើតផលចំរើនដល់ពួកទាយកទាយិកា ញ៉ាំងសេចក្ដីរីករាយឲ្យកើតឡើងដល់ពួកទាយកទាយិកា បើទុកជាឲ្យតិចក៏បានផលច្រើនជាអនេក បើបានជាឲ្យច្រើន រឹតតែមានផលចំរើនឡើងទៅទៀត ។

## អង្គ ៣ របស់កែវមណី ៖

១ — មានសាច់ល្អបំផុត ។

២ — មិនប្រឡាក់ដោយគ្រឿងសៅហ្មងយ៉ាងណាមួយឡើយ ។

៣ — ប្រភេទកែវមណីក៏នៅនឹងប្រភេទកែវមណីផងគ្នា ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៣ ប្រការគឺ ៖

១ — ចិញ្ចឹមជីវិតបរិសុទ្ធិហ្មត់ចត់ជាបំផុត ។

២ — មិនប្រឡូកប្រឡល់ដោយបាបមិត្រ ដែលមានចិត្តអាក្រក់ថោកទាប ។

៣ — នៅរួមតែនឹងអ្នកដែលមានជាតិឧត្តមប្រសើរ មានសេចក្ដីបរិសុទ្ធិហ្មត់ចត់ដូចគ្នា ។

## ពួកមានអង្គ ៤

### អង្គ ៤ របស់ស្ដេចចក្រពត្តិ ៖

១ — ទ្រង់ថែរក្សាទឹកចិត្តរបស់ប្រជាជនដោយសង្គហវត្ថុ ៤ ប្រការ ។

២- ពួកចោរជាសត្រូវនឹងផែនដីមិនមានកើតឡើងក្នុងរាជអាណាចក្រឡើយ ។

៣- តែងទ្រង់ពិចារណាអំពីសេចក្ដីល្អអាក្រក់ ទ្រង់ណែនាំប្រជានុរាស្ត្រទាំងផែនដីដ៏ទូលាយ មានមហាសមុទ្រជាទីបំផុត ឲ្យប្រតិបត្តិតាមគន្លងធម៌ ។

៤- ទ្រង់ចាត់ការគ្រប់គ្រងការពាររាជអាណាចក្រយ៉ាងម៉ឺងម៉ាត់ ឲ្យមានការក្ដាប់ទាំងខាងក្នុងទាំងខាងក្រៅ ។

របៀបដូចអ្នកប្រតិបត្តិប្រកបដោយអត្ថសម្បត្តិ ៤ ប្រការ :

១- ថែរក្សាទឹកចិត្តរបស់បរិស័ទ អនុគ្រោះបរិស័ទឲ្យមានចិត្តសប្បាយរីករាយ ។

២- កាមវិតក្ក ព្យាបាទវិតក្ក វិហិង្សាវិតក្ក ដូចជាខ្មាំងសត្រូវ មិនមានកើតឡើងក្នុងសន្ដានចិត្តឡើយ ។

៣- តែងពិចារណាជម្រះជុះខាត់កាយកម្ម វចីកម្ម មនោកម្ម សព្វៗថ្ងៃថា យប់ថ្ងៃដែលកន្លងទៅ មានបើប៉ះពាល់ដោយហេតុទាំង ៣ នេះខ្លះឬទេ ។

៤- តាំងប្រុងស្មារតីដូចជានាយទ្វារឲ្យនៅចាំប្រុងប្រយ័ត្ន ក្នុងកិលេសទាំងខាងក្នុង ទាំងខាងក្រៅ ។

(មានត)

# ពិធីព្រះរាជទានសមណស័ក្តិ

## ទីសម្ដេច នឹងទីរាជាគណៈវត្តបទុមវតី

នៅថ្ងៃព្រហស្បតិ៍-សុក្រ-សៅរ៍ ៣-៤-៥ កើតខែអស្សុជ ឆ្នាំវកសក ព.ស. ២៤៨៧ ត្រូវនឹងថ្ងៃ ៥-៦-៧ ខែអុកតូប្រឆ្នាំ ១៩៤៤ វេលាម៉ោង ៨ យប់ និមន្តព្រះសង្ឃ ២៥ អង្គចំរើនព្រះបរិត្តក្នុងវិហារវត្តបទុមវតី គ្រប់ទាំង ៣ ថ្ងៃខាងលើនេះ ។

ដល់ថ្ងៃអាទិត្យ ៦ កើតខែអស្សុជ ៨ អុកតូប្រឆ្នាំនេះ វេលាម៉ោង ៩ និង៣០ នាទី ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងលោករ៉េស៊ីដង់ស៊ុប៉េរីយើរ ទ្រង់ស្ដេចយាង-អញ្ជើញដល់វត្តបទុមវតី មានក្រុមរក្សាព្រះអង្គនិងក្រុមភ្លេងសម្រាប់កង្យចាំទទួល លុះព្រះករុណានិងលោកនាយកកម្ពុជាស្ដេចយាង-អញ្ជើញចូលទៅក្នុងវិហាររួចហើយ ទើបលោក (ញឹក-នូ) យកផ្កា ១ កម្រងថ្វាយព្រះករុណា លោកឧកញ៉ាទេពពិទូរ (ក្រសេម) យកផ្កា ១ កម្រងជូនលោកនាយកប្រទេសកម្ពុជា ធ្វើសក្ការបូជាព្រះរតនត្រ័យ ស្រេចហើយលោកអ្នកឧកញ៉ាអគ្គមហាសេនា (អ៊ឹង-អ៊ី) សេនាបតីក្រសួងវាំង, ព្រះឃ្លាំងនឹងធម្មការបានហៅនាមព្រះមហាថេរដែលត្រូវឡើងសមណស័ក្តិជាន់ខ្ពស់ ឲ្យនិមន្តចូលមួយអង្គម្ដងៗតាមលំដាប់ លោកនាយកប្រទេសកម្ពុជាបានប្រគេនសញ្ញាប័ត្រព្រះករុណាទ្រង់ប្រោសព្រះរាជទានផ្ដិតសមណស័ក្តិ ដែលត្រូវតាមសញ្ញាប័ត្រនោះដល់ព្រះសង្ឃទាំង ៥ អង្គគឺ៖

១- ព្រះសុធម្មាធិបតី ( អ៊ុក-ស្រី ) បានឡើងសមណស័ក្តិជា សម្តេចព្រះសុធម្មាធិបតី សង្ឃនាយកគណៈធម្មយុត្តិ វត្តបទុមវតី ។

២ - ព្រះវិមលធម្ម (កែប - កួន ) បានឡើងសមណស័ក្តិជាព្រះ មង្គលទេពាចារ្យ រាជាគណៈសម្រាប់ឯក វត្តបទុមវតី ។

៣ - ព្រះញាណវិរិយៈ ( លឿង ) បានឡើងសមណស័ក្តិជាព្រះ ធម្មការវង្ស សម្រាប់ត្រី ចៅអធិការ វត្តខ្ទូមណីកេ ។

៤ - ព្រះអមរាភិរក្ខិត (ជុំ) បានឡើងសមណស័ក្តិជាព្រះឧបាលិ-វង្សរាជាគណៈសម្រាប់ត្រី វត្តបទុមវតី ។

៥ - ព្រះវេទីមេធា (កែវ-អ៊ូច ) បានឡើងសមណស័ក្តិជាព្រះ អរិយគស្សប រាជាគណៈសម្រាប់ត្រី វត្តបទុមវតី ។

កាលស្រេចកិច្ចប្រគេនសញ្ញាប័ត្រនិងជ្ញីកនេះហើយ ទើបព្រះករុណា, លោកនាយកប្រទេសកម្ពុជា, សម្តេចព្រះសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ, និងអស់លោក-អ្នកដែលបានអញ្ជើញមកក្នុងមហាសន្និបាតនេះទាំងអស់ បានថ្លែងស័ព្ទសាធុការពរប្រគេនចំពោះ សម្តេចព្រះសុធម្មាធិបតី ដើម្បីឲ្យមានសិរីសួស្តីជ័យមង្គលតទៅ សម្តេចព្រះសុធម្មាធិបតី ក៏បានថ្លែងសុន្ទរកថាទទួលសេចក្តីអំណររបស់លោកតបវិញ ។

លុះប្រគេនស័ព្ទសាធុការពររួចហើយ នៅវេលាម៉ោង ១០ គេបាននិមន្តសម្តេចព្រះសុធម្មាធិបតីចេញពីក្នុងវិហារ ទៅគង់លើកន្លែងដែល

ធ្វើលើកើយវិហារខាងមុខ មានកំពូលស្រួច ប្រដាប់ដោយក្បាច់រចនា ក្ផ្កាយ៉ាងស្រស់ វេលានោះ ព្រះករុណា ទ្រង់ស្ដេចយាងទៅប្រថាប់ពី ខាងមុខកនមា ហើយទ្រង់ប្រោសព្រះរាជទានស្រោចទឹកមន្តលើព្រះ ហស្ត សម្ដេចព្រះសុធម្មាធិបតី បន្ទាប់មកលោកនាយកកម្ពុជា សម្ដេច ព្រះសុមេធាធិបតី ព្រមទាំងអស់លោករដ្ឋមន្ត្រីចូលស្រោចរៀងគ្នាជា លំដាប់ ចំណែកព្រះសង្ឃទាំងពួងដែលគង់ក្នុងវិហារក៏សូត្រធម៌ជ-យន្តោចំរើនពរជ័យមង្គល ទាំងភ្លេងដូរ្យតន្ត្រីកំបន្ទីសូរស័ព្ទកងរំពង ព្រមគ្នាជាសញ្ញាសំគាល់ថាបានប្រគេនទក្ខិណោទក ចំពោះសម្ដេចព្រះ សុធម្មាធិបតី នៅវេលាស្រេចកិច្ចនេះហើយ ព្រះករុណា និងលោក នាយកប្រទេសកម្ពុជា ទ្រង់ស្ដេចយាង-អញ្ជើញត្រឡប់ទៅវិញ នៅ វេលាម៉ោង ១០ និង ២០ នាទី ។

☼

☼ ☼

ដល់ថ្ងៃចន្ទ ៩ ឧកតូប្រ៍ ក្រុមឧបាសក-សិកា ចំណុះវត្តបទុមវតី ទាំងអស់មានព្រះសុធម្មប្រីជា ( ងន ) អាចារ្យសម្រាប់វត្តជាប្រធាន បានតាក់តែងចង្ហាន់និមន្តព្រះសង្ឃ ៧៥ អង្គទទួលបិណ្ឌបាតនៅមុខវិ-ហារ ក្នុងវេលាម៉ោង ៨ ព្រឹកជាកិច្ចបង្ហើយពិធីបុណ្យត្រៃមាសបុណ្ណះ ។

មួយទៀត ក្នុងពិធីបុណ្យសម្ពោធនេះ គេសង្កេតឃើញថាជាទីរុង-រឿងដ៏ឧឡារិក ដោយមានធ្វើស៊ុំក្លោងទ្វារ ១ ចំពីខាងមុខវិហារ មាន ថ្នាក់ ២ ខ្ពង់នៅអមសងខាងស៊ុំទ្វារនេះ ប្រដាប់ដោយទង់ជាតិដ៏ដេរ

ដាស ជាកន្លែងសម្រាប់ទទួលអស់លោកមន្ត្រីធំ-តូច ដែលអញ្ជើញមកក្នុងមហាសន្និបាតនោះដោយសេចក្តីរីករាយសាទរ ។

ចំណែកខាងបព្វជិតគឺ: សម្តេចព្រះមហាសុមេធាធិបតី ( ហ៊ុន ) សង្ឃនាយកគណៈមហានិកាយ, ព្រះពោធិវង្ស (ជួន-ណាត) បានហាងសាលាបាលីជាន់ខ្ពស់ និងជាចៅអធិការវត្តឧណ្ណាលោម, ព្រះមហាព្រហ្មមុនី (ទេព-អ៊ូ) បានហាងនៃសាលាបាលីជាន់ខ្ពស់ និងជាចៅអធិការវត្តស្វាយពពែ (ទីរៀនហ៊ុង), ព្រះមហាវិមលធម្ម (ហួត-តាត) អធិបតីក្រុមជំនុំព្រះត្រៃបិដកក្រសួងពុទ្ធសាសនបណ្ឌិត្យ ព្រមទាំងព្រះមហាថេរានុត្ថេរជាច្រើនអង្គទៀត ។

ប៉ែកខាងគ្រហស្ថគឺ: (ក្រៅអំពីព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងលោកឡឺរេស៊ីដង់ស៊ុបេរីយើរកម្ពុជរដ្ឋ) មានលោក ជីឡង់ នាយកពជការក្រុមមឿង, លោកបារ៉ូ ដេឡេគេនៅឯមកជការខ្មែរ, លោកខូយ-ប៊ុនតិ៍ អគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ, លោកដេឡេគេក្នុងព្រះបរមរាជវាំង និងលោកគណរដ្ឋមន្ត្រីទាំងអស់ មានលោកអ្នកឧកញ៉ាអគ្គមហាសេនា (ភីង-អ៊ី) សេនាបតីក្រសួងក្រុងព្រះឃ្លាំងនិងធម្មការជាដើម ។

ចំណែកពួកឧបាសក-ឧបាសិកាជើងវត្តបទុមវតី ក៏ព្រមព្រៀងគ្នាមូលមកជួបជុំគ្នាយ៉ាងបង្អៀតក្នុងទីព្រះវិហារ សូម្បីនៅទីលានខាងមុខព្រះវិហារក៏មានមនុស្សប្រុសស្រីក្មេងចាស់ឈរកុះករជាច្រើនណាស់ដែរ ។

# កែពាក្យខុស

សៀវភៅលេខ ១០ ទំព័រ ៤១០ បន្ទាត់ ១ បណ្ដាក់

ទី ៤៧ ពាក្យថា មានបន្លា . . .

សូមកែថា មានបន្លាដុំខ្លួន . . .

សៀវភៅលេខ ១០ ទំព័រ ៤២២ បន្ទាត់ ១៦

ពាក្យថា ឃើញពួកគេ . . .

សូមកែថា ឃើញពូគេ . . .